# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*ខ្ញុំឃើញគេជម្លៀសប្រជាជនទាំងចាស់ ទាំងក្មេង ទាំងកូនង៉ែត ទាំងស្រីៗដែលទើបកើតកូន។*
*ហើយស្រីៗដែលកើតកូន និងកូនង៉ែតមិនសូវមានសង្ឃឹមនឹងរស់។*[1]

- **លោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍** (François Ponchaud)

## ផ្នែកទី ១៖ និដ្ឋភាពទូទៅ

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីលោក **ឆោម សែ** និងបានស្តាប់សក្ខីកម្មទាំងស្រុងរបស់សាក្សីលោក **ហ្វ្រង់ស្វ័រ ប៉ុងសូដ៍** (François Ponchaud)។ លោក **ឆោម សែ** បានបន្តផ្តល់សក្ខីកម្មរបស់គាត់ បន្ទាប់ពីមានការផ្អាកសវនាការជាបណ្តោះអាសន្នមួយ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ដោយសារតែជំងឺរបស់សហជនជាប់ចោទ និងបញ្ហាដែលត្រូវដោះស្រាយដទៃទៀត។[2] លោក **ហ្វ្រង់ស្វ័រ ប៉ុងសូដ៍** ដែលជាសាសនិកជន ជនជាតិបារាំង និងជាអ្នកនិពន្ធសៀវភៅឈ្មោះ "ប្រទេសកម្ពុជា៖ ឆ្នាំសូន្យ" បានចាប់ផ្តើមផ្តល់សក្ខីកម្មរបស់គាត់នៅថ្ងៃអង្គារ។ ថ្វីបើគាត់អាចនិយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញក៏ដោយ ក៏ការសម្រេចចិត្តផ្តល់សក្ខីកម្មជាភាសាខ្មែររបស់គាត់ បានបង្កឲ្យមានបញ្ហាបកប្រែកើតមានឡើងជាបន្តបន្ទាប់ នៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មផងដែរ ហើយការគិតគូរផ្តល់ពេលវេលាបន្ថែមត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់ពីការឆ្លើយតបរបស់គាត់។

ការជំទាស់ជាច្រើន ត្រូវបានលើកឡើងពេញមួយសប្តាហ៍នេះ ទាក់ទងនឹងការដកស្រង់ពាក្យចចាមអារ៉ាម និងការសួរសំណួរក្រៅវិសាលភាពនៃសំណុំរឿង០០២/០១។ ក្រុមមេធាវីការពារក្តី បានជំទាស់ជាច្រើនលើកច្រើនសាចំពោះសាក្សី **ប៉ុងសូដ៍** ដែលបានផ្តល់នូវភស្តុតាងជាលក្ខណៈគំនិតយោបល់ផ្ទាល់ខ្លួន និងបែបសន្និដ្ឋាន ដែលមើលទៅហាក់ដូចជាទទួលបាននូវភាពអត់ធ្មត់ជាទីបំផុត ពីសំណាក់អង្គជំនុំជម្រះ ហើយក៏មានករណីលើកលែងមួយផងដែរ នៅពេលដែលអង្គជំនុំជម្រះបានយល់ស្របចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្តី។ កាលពីថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះ ក៏បានស្តាប់សេចក្តីសម្អាងហេតុពាក់ព័ន្ធនឹងបណ្តឹងរបស់ជនជាប់ចោទ **ខៀវ សំផន** ក្នុងការសុំឲ្យមានការដោះលែងនៅក្រៅឃុំជាបណ្តោះអាសន្ន មុននឹងមានការ

ពិភាក្សាដេញដោលលើភាពទទួលយកបាននៃភស្តុតាងថ្មី ដែលខាងការិយាល័យសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** មានបំណងលើកយកមកសម្អាងក្នុងអំឡុងពេលនៃសវនាការ។

## ផ្នែកទី ២ ៖ សក្ខីកម្មសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

នាសប្តាហ៍នេះ មានសាក្សីចំនួនពីររូប បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ លោក **ឆោម សែ** ជាអតីតប្រធានមន្ទីរសន្តិសុខ អូរកន្សែង នៅភូមិភាគឦសាន បានមកផ្តល់សក្ខីកម្មអំពីការរំដោះទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ និងកិច្ចការងារបន្តបន្ទាប់មកទៀតរបស់គាត់ នៅក្នុងមន្ទីរសន្តិសុខនៃកងពល៨០១។ បន្ទាប់មក សាក្សី **ហ្វ្រង់ស្វ័រ ប៉ុងសូដ៍** បានរស់នៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៦៥ រហូតដល់មានការជម្លៀសគាត់ចេញពីស្ថានទូតបារាំងក្នុងឆ្នាំ១៩៧៥។ ជាកិច្ចបន្ថែមពីកិច្ចស្រាវជ្រាវរបស់គាត់ ដោយបានធ្វើឡើងជាមួយនឹងជនភៀសខ្លួនកម្ពុជា ដែលបានរត់ភៀសខ្លួនចេញពីប្រទេស សាក្សីបានផ្តល់នូវការយល់ដឹងដ៏ស៊ីជម្រៅពីព្រឹត្តិការជាច្រើន ដែលបណ្តាលឲ្យកើតមានការដួលរំលំរាជធានីភ្នំពេញ និងក្រោយពេលដែលទីក្រុងធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់កងទ័ពខ្មែរក្រហម។

### ក. សក្ខីកម្មរបស់លោក ឆោម សែ

មានតួនាទីជាសមាជិកកងភូមិភាគឦសាន ដែលធ្លាប់ពាក់ព័ន្ធនឹងការវាយរំដោះទីក្រុងភ្នំពេញកាលពីខែមេសា ឆ្នាំ១៩៧៥ និងជាអតីតប្រធានមន្ទីរសន្តិសុខ អូរកន្សែង ក្នុងកងពលលេខ៨០១ លោក **ឆោម សែ** បានផ្តល់នូវការយល់ដឹងដ៏ស៊ីជម្រៅយ៉ាងសំខាន់ស្តីពីរចនាសម្ព័ន្ធ ទំនាក់ទំនង និងប្រតិបត្តិការយោធាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។[3]

#### *ក.១. បទពិសោធន៍មុន និងក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

ក្រោយពីបានចូលរួមចលនាបដិវត្តន៍ក្នុងឆ្នាំ១៩៧០ លោក **ឆោម សែ** បានបម្រើការជាយោធិននៅក្នុងខេត្តកំពង់ស្ពឺ ដែលមានទីតាំងក្នុងភូមិភាគនិរតី។ គាត់បានពន្យល់ថា អ្វីដែលជំរុញទឹកចិត្តរបស់គាត់ក្នុងការចូលរួមចលនាបដិវត្តន៍ គឺសំខាន់បំផុតដោយសារមានការអំពាវនាវពី **សម្តេច នរោត្តមសីហនុ** ដើម្បីរួបរួមកម្លាំងទ័ពប្រឆាំងនឹងរបប លន់ នល់ ។ គាត់ក៏ត្រូវបានបង្ខំរត់ភៀសខ្លួនផងដែរ ដោយសារតែហេតុផលថា ភូមិរបស់គាត់មានទីតាំងស្ថិតនៅតាមបណ្តោយព្រំដែនប្រទេសវៀតណាម បានទទួលរងនូវការទម្លាក់គ្រាប់បែក និងការគំរាមកំហែងពីការទន្ទ្រានរបស់កងទ័ពវៀតណាមខាងត្បូង។ ក្នុងការឆ្លើយតបទៅនឹងសំណួរពីសំណាក់មេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** គឺលោក **វិចទ័រ កូប៉េ** សាក្សីបានបដិសេធថា ទង្វើរបស់កងទ័ព **លន់ នល់** បានជំរុញឲ្យគាត់សម្រេចចិត្តចូលរួមបដិវត្តន៍។ នៅក្រោមការបញ្ជារបស់ **សូរ សារឿន** គាត់បានទទួលវគ្គបណ្តុះបណ្តាលយោធាមួយចំនួន ហើយកងវរសេនាធំរបស់គាត់បានវាយប្រយុទ្ធជាមួយនឹងកងទ័ព **យៀកកុង** (Viet Cong) ។ លោក **ឆោម សែ** បានផ្តល់សក្ខីកម្មថា យោងតាមសីលធម៌ទាំង ១២ ប្រការ ដែលកងទ័ពរំដោះទាមទារឲ្យគោរពជាដាច់ខាត អង្គភាពរបស់គាត់ មិនលួចប្លន់ទ្រព្យសម្បត្តិ ឬប្រព្រឹត្ត "អំពើបំពាន សម្លុត គំរាមកំហែង ចំពោះប្រជាជន" ឡើយ។ គាត់បានអះអាងថា គាត់មិនបានដឹងពីការប្រព្រឹត្តិអំពើអសីលធម៌ណាមួយ ឬអំពើពុករលួយក្នុងជួរកងទ័ពរបស់គាត់ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន

ចេញពីទីក្រុងក្នុងឆ្នាំ១៩៧៥ឡើយ ហើយគាត់បានបន្ថែមទៀតថា ខ្មាំងសត្រូវដែលរឹងរូស ត្រូវបានយកទៅព្រមាន ក៏ប៉ុន្តែមិនដែលយកទៅសម្លាប់តាមតែទំនើងចិត្តរបស់ខ្លួននោះទេ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីរូបនេះ បានឡើងកាន់តួនាទីជាអនុប្រធានកងវរសេនាធំទទួលខុសត្រូវដឹកនាំអង្គភាពមួយ ដែលមានកងទ័ពប្រហែលជា ១០០នាក់ ដើម្បីវាយយកទីក្រុងភ្នំពេញតាមច្រកពោធិ៍ចិនតុង។ គាត់បានរំឭកពីការទទួលបញ្ជាពីអគ្គមេបញ្ជាការកងទ័ព **ឈិត ជឿន** ហៅ **ម៉ុក** តាមរយៈ **សួរ សារឿន** ឲ្យធ្វើការវាយលុក។ ក្រោយពីការដួលរំលំទីក្រុងភ្នំពេញ អង្គភាពរបស់គាត់បានឈរជើងនៅក្បែរផ្សារថ្មី ដោយមានបទបញ្ជាណែនាំឲ្យធានាសន្តិសុខនៅក្នុងតំបន់នោះ ពោលគឺជាតំបន់ដែលបាន "កាន់កាប់" ហើយក្រោយមក ក៏បានជម្លៀសប្រជាជនចេញ។ គាត់បានកត់សម្គាល់ថា ទោះបីជារាជធានីត្រូវបានរំដោះក៏ដោយ ប៉ុន្តែក៏នៅតែមានបទបញ្ជាឲ្យធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក្នុងគោលបំណងបញ្ចៀសការវាយប្រហារ តបតមកវិញពីកងទ័ពបរាជ័យ ដែលនៅសេសសល់ពីរបប **លន់ នល់**។ មេធាវីការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន** គឺលោក **អាកទ័រ វ៉ែកគែន** (Arthur Vercken) មានគោលបំណងបង្ហាញពីការបន្លាស់ទីប្រជាជន គឺជាការវិធានការការពារដ៏ចាំបាច់បំផុតសម្រាប់កងទ័ព ហើយវាមិនមែនជាការធ្វើទារុណកម្មមកលើប្រជាជននៅទីក្រុងឡើយ។ បន្ទាប់មក សាក្សីរូបនេះ ក៏បានអះអាងយល់ស្របនឹងការលើកឡើងខាងលើនេះ។ លោក **ឆោម សែ** បានផ្តល់សក្ខីកម្មថា គាត់មិនជឿថា ការជម្លៀសប្រជាជនគឺជាការធ្វើដោយបង្ខំឡើយ គឺដោយសារតែវាត្រូវចំណាយពេលអស់៧ថ្ងៃ មុនពេលដែលប្រជាជនទាំងនោះបានចាកចេញអស់ពីទីក្រុង។ គាត់បានពន្យល់ថា ការជម្លៀសប្រជាជននៅក្រោមអង្គភាពរបស់គាត់មានសភាពស្ងប់ស្ងាត់ គ្មានការវាយតបតគ្នា តែទោះបីជាយ៉ាងក៏ដោយ គាត់បានឮថា មានតំបន់ដទៃបានតបតជាមួយប្រជាជន ដែលធ្វើការតស៊ូ ឬលាក់បាំងព័ត៌មាន។ គាត់បានបញ្ជាក់ថា ប្រជាជនដែលត្រូវបានគេវាយធ្វើបាបទាំងនោះ ទំនងជាត្រូវបានគេព្រមានឲ្យចាកចេញ ក៏ប៉ុន្តែមិនដល់ថ្នាក់ធ្វើឲ្យមានការខឹងសម្បាអ្វីឡើយ។

សាក្សី ក៏បានរំឭកពីការចូលរួមកិច្ចប្រជុំសន្និបាតមួយធ្វើឡើងនៅស្តាតអូឡាំពិក ក្នុងឆ្នាំ១៩៧៥ ដែលកងពលលេខ៨០១ ត្រូវបានបង្កើតឡើង ហើយមេដឹកនាំជាន់ខ្ពស់នៃរបបថ្មីនេះត្រូវប្រកាសឈ្មោះ។ គាត់បានបញ្ជាក់ថា មានមេដឹកនាំចំនួន ២១នាក់ មានវត្តមានក្នុងសន្និបាតនោះ ហើយគាត់បានដឹងរឿងនេះ តាមរយៈការអាន *ទស្សនាវដ្តីទង់បដិវត្តន៍* ចំនួនពីរលេខ ដែលគាត់បានទទួលក្រោយពេលសន្និបាតនេះចប់។ គាត់មិនអាចចងចាំឈ្មោះរបស់មេបញ្ជាការ ដែលបានប្រកាសការតែងតាំងសាជាថ្មី ពីការកាន់កាប់កងពលលេខ៨០១ ទៅកាន់ភូមិភាគឦសាននោះទេ ក៏ប៉ុន្តែគាត់បាននិយាយថា វាអាចជាលោក **សុន សេន** ឬលោក **ឈិត ជឿន**។ គាត់បានកត់សម្គាល់ឃើញថា លោក **ខៀវ សំផន** ក៏មានវត្តមានផងដែរ ដោយសារគាត់មានតំណែងជាប្រធានគណៈប្រធានរដ្ឋ ទោះបីជាពេលនោះ សាក្សីមិនបានដឹងពីឋានៈរបស់ជនជាប់ចោទរូបនេះក៏ដោយ។

### *ក.២. ការយល់ដឹងស្តីពីចេនាសម្ព័ន្ធបញ្ជានៅកងពល៨០១ និងភូមិភាគឦសាន*

នៅចុងឆ្នាំ១៩៧៥ លោក **ឆោម សែ** បានធ្វើដំណើរទៅកាន់ភូមិភាគឦសាន ជាមួយនឹងកងពលយោធា៨០១ ហើយនៅឆ្នាំ១៩៧៦ គាត់ត្រូវបានតែងតាំងជាប្រធានមន្ទីរអប់រំរៀនសូត្រអូរកន្សែង ក្បែរស្រុកបានលុង។ នៅពេលដែលមានសំណួរសួរថា តើហេតុផលអ្វីបានគាត់ត្រូវបានជ្រើសរើសឲ្យក្លាយជាប្រធាន គាត់ហាក់ដូចជាមានការពិបាកក្នុងការឆ្លើយតបនឹងសំណួរនេះ។ គាត់បានសន្និដ្ឋានថា គេជ្រើសរើសគាត់ឲ្យ

កាន់តំណែង ដោយសារតែការប្តេជ្ញាចិត្តដ៏រឹងមាំ និងការបំពេញតួនាទីជានីរសារ (អ្នកនាំសារ) ឲ្យលោក **សួរ សារឿន** (នៅពេលដែល **សួរ សារឿន** បានធ្វើជាមេកងពល និងក្រោយមកធ្វើជាមេភូមិភាគ)។ សាក្សី បានកត់សម្គាល់ថា **សួរ សារឿន** មានភាពជឿជាក់មកលើរូបគាត់ ដោយបានចាត់ទុកគាត់ដូចជា "បងប្អូនប្រុស ឬជាក្មួយប្រុសអ៊ីចឹង"។[4]

លោក **ឆោម សែ** បានផ្តល់សក្ខីកម្មថា **សួរ សារឿន** ជាញឹកញាប់បានធ្វើដំណើរឡើងចុះៗពីភូមិភាគព្យសាន ទៅកាន់ទីក្រុងភ្នំពេញជារៀងរាល់ឆ្នាំ។ នៅពេលដែលមេបញ្ជាការរបស់គាត់បានវិលត្រឡប់ពីកិច្ចប្រជុំនៅរាជធានីវិញ សាក្សីបានពន្យល់ថា **សួរ សារឿន** បានផ្សព្វផ្សាយព័ត៌មានទៅកាន់កងពលទាំងមូលស្តីពីវិធីសាស្ត្រនៃការអនុវត្តគម្រោងដើម្បី "ការពារប្រទេសជាតិ និងបង្កបង្កើនផលកសិកម្ម"។ កម្មាភិបាលជាន់ទាបរបស់កងពល៨០១ ទាំងអស់ ក៏ត្រូវបានស្នើឲ្យពង្រឹងកម្លាំងទ័ពរបស់ខ្លួន ខិតខំបំពាក់បំប៉នប្រជាជនឲ្យគោរពតាម "បទបញ្ជាថ្នាក់លើ កាត់បន្ថយសត្រូវ ហើយបង្កើនមិត្តឲ្យជ្រាលជ្រៅឡើងវិញ" ក្នុងចំណោមសមាសភាពទាំងអស់។ ក្នុងការឆ្លើយតបទៅនឹងសំណួរសួរដោយមេធាវី **កូប៉េ** សាក្សីបានអះអាងថា គាត់បានប្រើប្រាស់ពាក្យ "ថ្នាក់លើ" មិនមែនសំដៅទៅលើរចនាសម្ព័ន្ធបទបញ្ជាពីលើមេរបស់គាត់ទេ ព្រោះលោក **សួរ សារឿង** មិនដែលបានទទួលបញ្ជាដោយផ្ទាល់ពីនរណាម្នាក់ឡើយ។

នៅឆ្នាំ១៩៧៧ លោក **កែវ សារឿន** (ជាមេបញ្ជាការកងវរសេនាធំ៨១ នៃកងពល៨០១) ត្រូវបានគេចាប់ខ្លួន ហើយលោក **ប៉ោ សំអុន** ក៏បានកាន់តំណែងជំនួសគាត់។ ដូចគ្នានឹងមេដឹកនាំ និងមេបញ្ជាការយោធាដទៃទៀតដែរ **កែវ សារឿន** ត្រូវបានស្នើឲ្យទៅរៀនវគ្គអប់រំរៀនសូត្រមួយនៅទីក្រុងភ្នំពេញ ហើយតាំងពីហ្នឹងមក គាត់មិនដែលវិលត្រឡប់មកភូមិភាគព្យសានវិញឡើយ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧ មានរបាយការណ៍មួយ ត្រូវបានផ្ញើពីកងពល៨០១ ទៅកាន់លោក **សុន សេន** ដោយស្នើសុំឲ្យ សមមិត្ត **ម៉ៅ** កាន់កាប់ជំតំណែងរបស់លោក **ប៉ៅ សំអុន**។ បន្ទាប់ពីសហព្រះរាជអាជ្ញា **វាំងសង់ វ៉ាយដ៍ ដេស្មាឯល** (Mr. Vincent de wilde d'Estmael) បានអានរបាយការណ៍នោះមក សាក្សីបានអះអាងថា លោក **ប៉ៅ សំអុន** បានដើរតាមគន្លងរបស់លោក **កែវ សារឿន** ដែរ ក៏ប៉ុន្តែតួនាទីរបស់គាត់ត្រូវបានជំនួសដោយសមមិត្ត **ម៉ៅ**។ លោក **ឆោម សែ** បានអះអាងថា ដោយសារតែមានឋានៈតូចតាច បានក្លាយទៅជាឧបសគ្គធ្វើឲ្យគាត់មិនអាចដឹងពីជោគវាសនាចុងក្រោយរបស់សមមិត្ត **ប៉ៅ សំអុន** ឡើយ។ សហព្រះរាជអាជ្ញា បានកត់សម្គាល់ឃើញឈ្មោះរបស់ **ប៉ៅ សំអុន** នៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១។

### *ក.៣. ប្រធានមន្ទីរសន្តិសុខ អូរកន្សែង*

សាក្សីបានអះអាងថា **សួរ សារឿន** មានអំណាចទាំងអស់ក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងការរំដោះ ឬការសម្លាប់អ្នកទោសនៅអូរកន្សែង។ គាត់បានរំឭកពីកិច្ចប្រជុំផ្ទាល់ខ្លួនជាមួយនឹង **សួរ សារឿន** ហើយបានរៀបរាប់ពីគោលបំណងរបស់ **សួរ សារឿន** ក្នុងការយកចិត្តទុកដាក់លើបញ្ហាសត្រូវខាងក្នុង ដែលកំពុងវាយលុកក្នុងកងពល៨០១។ តាមឲ្យដឹងមក លោក **សួរ សារឿន** បានពន្យល់ថា ការយកចម្លើយសារភាពមានសារៈសំខាន់ណាស់ក្នុងការដឹងពីរឿងរ៉ាវជាប់ពាក់ព័ន្ធទាំងអស់ ជាពិសេស ដើម្បីកំណត់មុខសញ្ញាសត្រូវហ្នឹង "ក្នុងកម្រិតស៊ីជម្រៅប៉ុណ្ណា"។ លោក **ឆោម សែ** បានបកស្រាយជូនមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ផេត វណ្ណលី** ថា ប្រជាជនស៊ីវិលដែលជាប់ឃុំនៅអូរកន្សែង ភាគច្រើនគឺជា

"ប្រជាជនមូលដ្ឋាន" ដែលត្រូវបានគេបញ្ជូនមក ដើម្បីធ្វើការអប់រំរៀនសូត្រ បន្ទាប់ពីពួកគេត្រូវគេបានឆ្លើយដាក់ដោយនរណាម្នាក់ ដែលមិនចូលចិត្តការនិយាយស្តីរបស់ពួកគេ។ នៅត្រង់ចំណុចនេះ បញ្ហាការបុគ្គលិកបានបញ្ជូនមនុស្សម្នាក់ឈ្មោះ **ណូ** ឲ្យមកធ្វើការនៅក្នុងមន្ទីរសន្តិសុខនេះ ដើម្បីតាមដាន "ប្រព័ន្ធទំនាក់ទំនងរបស់ខ្មាំង" រួមទាំង "ខ្មាំងខាងក្នុង" ហើយនិងប្រមូលឯកសារមួយចំនួនផងដែរ។[5] គាត់ក៏បានរ៉ាយរ៉ាប់ពីការផ្តល់មេរៀនដល់ប្រជាជនស៊ីវិល ពីរបៀបនៃការកសាងខ្លួន ហើយនិងការកែប្រែអាកប្បកិរិយារបស់ពួកគេ។

នៅក្នុងចំណុចផ្សេងៗទៀតនៃសក្ខីកម្មរបស់គាត់ សាក្សីរូបនេះ បានលើកឡើងពីស្ថានភាពមួយ ដែលស្ថិតនៅក្រោមបញ្ជារបស់ **សូ សារឿន** មានជនជាតិភាគតិចចារ៉ាយជាង ១០០នាក់ រាប់បញ្ចូលមនុស្សស្រីគ្រប់វ័យទាំងអស់ ត្រូវបានចាប់ខ្លួនដោយកងទ័ពសមរភូមិមុខ បន្ទាប់ពីពួកគេបានដើរឆ្លងចូលព្រំដែនពីប្រទេសវៀតណាម។ អ្នកភូមិទាំងនោះ ត្រូវបានដឹកជញ្ជូនទៅកាន់មន្ទីរឃុំឃាំងអស់មួយយប់ ហើយបន្ទាប់មកក៏ត្រូវបានបញ្ជូនទៅសម្លាប់ចោល។ សហព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល** បានដកស្រង់សារទូរលេខមួយ ដែលសាក្សីរូបនេះបានរៀបរាប់បញ្ជាក់ថា សារទូរលេខនេះបានផ្ញើមកពីមនុស្សម្នាក់ឈ្មោះ **វី**[6] ជូនទៅ "អ៊ំ នួន បង វ៉ាន់ (របស្សនាមរបស់ **អៀង សារី**) បង **ផួង** បង **ខៀវ** (របស្សនាមរបស់ **សុន សេន**) មន្ទីរ និងឯកសារ"។ នៅក្នុងកថាខណ្ឌទី៣ នៃសារទូរលេខ **វី** បានរៀបរាប់ពីប្រជាជនចារ៉ាយថា ជា "ខ្មាំងខាងក្រៅ ដែលចង់ចូលមកក្នុងទឹកដីរបស់យើង" ហើយបានសរសេរថា "សុំមតិអង្គការថែម តាមកងផលិត៨០១ស្នើសម្រេចកម្រិតខ្ពស់តែម្តង។ ខ្ញុំរង់ចាំចម្លើយយល់ព្រមសម្រេចរបៀបនេះ"។[7] សាក្សី **ឆោម សែ** បានបញ្ជាក់ថា ក្រុមដែលបានរៀបរាប់ក្នុងសារទូរលេខ ស្រដៀងគ្នានឹងប្រជាជនចារ៉ាយនោះ បានទទួលស្វាគមន៍នៅកន្លែងរបស់គាត់នោះដែរ។ គាត់ក៏បានបញ្ជាក់ផងដែរថា កងពល៨០១ តែងតែស្នើសុំការណែនាំពីមជ្ឈិម តាមរយៈសារទូរលេខស្រដៀងគ្នានេះ។

សាក្សី បានពិពណ៌នាពីចំនួនអ្នកទោសក្នុងមន្ទីរសន្តិសុខនេះ ដែលបានកើនឡើងប្រហែលចាប់ពី ៥០នាក់ ទៅដល់១០០នាក់ ដោយសារតែមានកម្មាភិបាលយោធាជាច្រើន បានចាប់ផ្តើមឆ្លើយដាក់គ្នាទៅវិញទៅមក ហើយការកម្ទេចក៏រឹតតែកើនឡើងខ្លាំងក្លាផងដែរ។ ប្រការបែបនេះ បានកើតឡើងដូចគ្នាផងដែរជាមួយនឹងស្ថានភាពកាន់តែរីកធំឡើង នៅតាមព្រំដែននៃប្រទេសវៀតណាម។ ទាក់ទិននឹងការប្រើទារុណកម្ម សាក្សី **ឆោម សែ** បានកត់សម្គាល់ថា ដំបូងឡើយ ពួកគេមិនអាចប្រើទារុណកម្មទៅលើជនដែលជាប់ឃុំឃាំងបានឡើយ ប្រសិនបើចម្លើយសារភាពនោះ "មិនត្រឹមត្រូវ" ក៏ប៉ុន្តែ ក្រោយមក ពួកគេត្រូវបានផ្តល់អំណាចក្នុងការធ្វើទារុណកម្ម បន្ទាប់ពីមានការសួរចម្លើយសាឡើងវិញ។ នៅពេលដែលមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** លោក **សុន អរុណ** បានចោទសួរទៅកាន់សាក្សី **ឆោម សែ** ថា តើគាត់ធ្លាប់បានសម្លាប់អ្នកដែលត្រូវចាប់ខ្លួនដែរ ឬទេ? មេធាវីប្រឹក្សាសាក្សី បានធ្វើអន្តរាគមន៍ ដោយបានបញ្ជាក់ថា ការឆ្លើយនឹងសំណួរនេះ អាចនឹងដាក់ពិរុទ្ធភាពមកលើសាក្សី។ លោកប្រធានអង្គជំនុំជម្រះ បានអនុញ្ញាតឲ្យសាក្សីរក្សាសិទ្ធិរបស់គាត់ ដោយមិនចាំបាច់ឆ្លើយនឹងសំណួរនេះ ហើយក៏បានក្រើនរម្លឹកដល់ភាគីថា ព្រឹត្តិការណ៍នានាក្នុងមន្ទីរសន្តិសុខនេះ មិនមែនជាចំណុចសំខាន់សម្រាប់ផ្តោតលើសវនាការនេះឡើយ។

### *ក.៤. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី*

ទោះបីជាសាក្សីបានសម្តែងពីឆន្ទៈនៃការផ្តល់ព័ត៌មាន និងភាពស្មោះត្រង់យ៉ាងច្រើនក្នុងការឆ្លើយសំណួរយ៉ាងណាក៏ដោយ ក៏នៅមានចំណុចពីរបី ដែលគាត់បានសម្រេចចិត្តមិនឆ្លើយតបទៅនឹងសំណួរមួយចំនួនផងដែរ ហើយប្រការបែបនេះ ប្រហែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់ភាពគួរឲ្យជឿជាក់លើចម្លើយរបស់គាត់។ មានពេលមួយ មេធាវី **វែកគែន** បានចោទសួរគាត់ឲ្យធ្វើការអះអាងលើសេចក្តីថ្លែងការណ៍មួយ ដែលគាត់បានធ្វើ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ដែលពាក់ព័ន្ធនឹងបញ្ជី "មហាជនក្បត់ទាំងប្រាំពីរនាក់" នៃរបប **លន់ នល់**។[8] ទោះបីជា មានការអានប្រតិចារឹកនៅខែមករានោះយ៉ាងឮៗឲ្យគាត់ស្តាប់ក៏ដោយ ក៏សាក្សីនៅតែបដិសេធមិនបានធ្វើសេចក្តីថ្លែងការណ៍ទាំងនោះដែរ។ នៅពេលមួយទៀតនោះ គឺពេលដែលមេធាវី **វែកគែន** បានចោទសួរពីរបៀបដែលគាត់ត្រូវបានគេជ្រើសរើសឲ្យឡើងកាន់តំណែងធ្វើជាមេបញ្ជាការអង្គភាពឃោធាមួយក្នុងឆ្នាំ១៩៧១ សាក្សី **ឆោម សែ** បានឆ្លើយតបវិញថា "ចម្លើយនេះ ដើម្បីកុំឲ្យពេលវេលាវែង ខ្ញុំបាទមិនចង់ឆ្លើយទេបាទ។ សូមអត់ទោសបាទ។"[9] វានៅតែមិនទាន់ច្បាស់ថា តើសាក្សីមានបំណងចង់គេចវេះឆ្លើយតបនឹងសំណួរ ឬក៏ទើសទាល់នឹងការឆ្លើយសំណួរនេះម្តងទៀត ដោយសារតែគាត់ធ្លាប់បានឆ្លើយសំណួរដដែលនេះ ពីសំណាក់មេធាវី **ជេត វណ្ណលី** រួចម្តងហើយ។ ទោះបីជាយ៉ាងនេះក្តី លោកប្រធានអង្គជំនុំជម្រះ បានអន្តរាគមន៍ ដោយបានក្រើនរម្លឹកដល់សាក្សីរូបនេះពីតួនាទីរបស់គាត់ ក្នុងការឆ្លើយតបរាល់សំណួរទាំងអស់ដោយសេចក្តីទៀងត្រង់ ល្មិកណាតែចម្លើយតបនោះដាក់ពិរុទ្ធភាពមកលើខ្លួនគាត់។

## ខ. សក្ខីកម្មរបស់សាក្សី ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ (François Ponchaud)

នៅថ្ងៃអង្គារ សាក្សី **ហ្វ្រង់ស្វ័រ ប៉ុងសូដ៍** (អត្តលេខ TCW-536) បានចាប់ផ្តើមផ្តល់សក្ខីកម្មរបស់គាត់។ លោក **ប៉ុងសូដ៍** បានផ្តល់សក្ខីកម្មថា គាត់បានរស់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង ៤៧ឆ្នាំមកហើយ និងធ្លាប់ឆ្លងកាត់បទពិសោធន៍ទាំងក្នុងរបប **សម្តេច នរោត្តមសីហនុ** និងរបប **លន់ នល់**។ ក្រោយពីបានឃើញដោយផ្ទាល់ភ្នែកពីការជម្លៀសរំលំទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មក គាត់បានភៀសខ្លួនមកស្នាក់នៅក្នុងស្ថានទូតបារាំង។ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៥ គាត់ជាជនបរទេសម្នាក់ក្នុងចំណោមជនបរទេសដែលត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជា។ គាត់បានមកផ្តល់សក្ខីកម្មចាប់តាំងពីថ្ងៃអង្គារ រហូតដល់ថ្ងៃព្រហស្បតិ៍ ស្តីពីស្ថានភាពក្នុងប្រទេសកម្ពុជានៅចន្លោះឆ្នាំ១៩៧០ និង១៩៧៥ ហើយនិងព្រឹត្តិការណ៍នានា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងចំនួនបទសម្ភាសន៍ ដែលគាត់បានធ្វើជាមួយនឹងជនភៀសខ្លួនកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៦។[10]

### *ខ.១. ស្ថានភាពក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥*

សាក្សី **ប៉ុងសូដ៍** បានសង្កត់ធ្ងន់ពីគោលបំណងមួយដើម្បី "យល់ដឹងអំពីរបៀបរបបរបស់ពួកខ្មែរក្រហម"។ គាត់បាននិយាយថា ដំបូងឡើយ ខ្មែរក្រហម "បានផ្តល់នូវសេចក្តីសង្ឃឹមដល់ប្រជាជនកម្ពុជា"។ គាត់បានពិពណ៌នាពីទុក្ខវេទនារបស់ប្រជាជនកម្ពុជា នៅមុនឆ្នាំ១៩៧៥ ទាំងក្នុងរបប **លន់ នល់** និងរបប **សម្តេច នរោត្តមសីហនុ**។ សាក្សី ក៏បានរម្លឹកឡើងវិញនូវរបាយការណ៍ដ៏ច្រើន ស្តីពីអំពើពុករលួយ និង

អំពើសាហាវព្រៃផ្សៃ នៅក្រោមរបបទាំងពីរនេះផងដែរ។ គាត់បានផ្តល់សក្ខីកម្មពីការបះបោរមួយនៅក្នុងឆ្នាំ ១៩៦៧ ប្រឆាំងនឹងរដ្ឋាភិបាលរបស់ **សម្តេចសីហនុ** បន្ទាប់ពីរដ្ឋាភិបាលបានផ្តួចផ្តើមយកដី ដើម្បីសង់រោងចក្រផលិតស្ករ នៅក្នុងស្រុកសំឡូត។ គាត់ក៏បានរៀបរាប់ពីឧបទ្ទវហេតុមួយ ដែលជាប់ពាក់ព័ន្ធនឹងកងទ័ព **លន់ នល់** ដែលបានបោកគ្រាប់បែកនៅស្គន់ ហើយបានសម្លាប់អ្នកតវ៉ាគ្មានអាវុធចំនួន ៦០នាក់ ក្នុងឆ្នាំ ១៩៧០ នៅក្រោយពេលដែល **សម្តេច នរោត្តមសីហនុ** ត្រូវបានទម្លាក់ចេញពីអំណាច។ ទាក់ទិននឹងការសាយភាយអំពើពុករលួយក្នុងរបប **សម្តេច សីហនុ** សាក្សីបានរៀបរាប់ពីរបៀបដែលលោក **ខៀវ សំផន** ត្រូវបានគេឲ្យកិត្តិនាមថា ជា "ជនស្អាតស្អំ" នាពេលនោះ លោក **ខៀវ សំផន** ត្រូវបានប៉ូលីសរដ្ឋាភិបាលចាប់សម្រាតខោអាវ នៅមុខរដ្ឋសភាពជាតិ។ លោក **ប៉ុងសូធ៍** បានឮថា ជនជាប់ចោទរូបនេះ នៅពេលនោះ ធ្លាប់ធ្វើជារដ្ឋលេខាធិការឲ្យក្រសួងពាណិជ្ជកម្ម ដែលបានបដិសេធទទួលយកសំណូក។ ក៏ប៉ុន្តែ នៅពេលដែលមានសំណួរពីសំណាក់ចៅក្រម **ឡាវែន៍** ស្តីពីបញ្ហាអំពើពុករលួយក្នុងអំឡុងពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ លោក **ប៉ុងសូធ៍** បានទទួលស្គាល់ថា ថ្វីបើមានអំពើពុករលួយក្នុងរបប **លន់ នល់** បានកើតឡើងយ៉ាងអាក្រក់យ៉ាងក៏ដោយ ក៏ស្ថានភាពវានៅតែល្អជាងកម្ពុជាសម័យបច្ចុប្បន្នដែរ។

ជាការគួរឲ្យកត់សម្គាល់ នៅក្នុងសក្ខីកម្មរបស់គាត់ទាំងអស់ សាក្សី **ប៉ុងសូធ៍** បានគូសបញ្ជាក់ពីតួនាទីស្នូលថា ការទម្លាក់គ្រាប់បែក និងគោលនយោបាយរបស់អាមេរិកកាំង ក្នុងអំឡុងពេលសង្គ្រាមឥណ្ឌូចិន បានដើរតួនាទីនៅក្នុងការឡើងកាន់អំណាចរបស់ខ្មែរក្រហម។ មានឱកាសជាច្រើនលើក ដែលសាក្សីបានបញ្ជាក់ថា **ហេនរី យីស៊ីងហ្គ័រ** (Henry Kissinger) គួរណាស់តែត្រូវយកមកកាត់ទោស ចំពោះការទម្លាក់គ្រាប់បែកដែលគាត់បានប៉ាន់ស្មាន បានសម្លាប់ប្រជាជនប្រហែល ៤០,០០០នាក់ និងបន្សល់ទុកនូវ "ទុក្ខវេទនា និងភាពភ័យខ្លាច" ដល់ប្រជាជនកម្ពុជា។ សាក្សី **ប៉ុងសូធ៍** បានរៀបរាប់ពីបទពិសោធន៍ដែលប្រជាជនកម្ពុជាបានរងគ្រោះនូវការទម្លាក់គ្រាប់បែកចំនួនពីរលើករបស់ "ឃាតករអាមេរិកកាំង"។ លើកទីមួយ បានទម្លាក់គ្រាប់បែកប្រហែល ១លានតោន នៅផ្នែកខាងកើតនៃប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៧០ ហើយបានបញ្ចេញនូវសារធាតុពណ៌ទឹកក្រូច (ថ្នាំគីមីក្នុងគ្រាប់បែក) ដែលបានបំផ្លិចបំផ្លាញចម្ការកៅស៊ូ សម្លាប់ប្រជាជនស៊ីវិល ហើយជាលទ្ធផលមានក្មេងខ្លះកើតមកពិការ កំបុតដៃ កំបុតជើងតែម្តង ដោយសារតែឥទ្ធិពលនៃថ្នាំគីមីដែលធ្លាក់ពីគ្រាប់បែកនោះ។ គាត់ក៏បានលើកឡើងពីការយោងដ៏ជាក់លាក់មួយ ទាក់ទងនឹងការសម្លាប់ និងការរំលោភប្រជាជនស៊ីវិល ក្នុងស្រុកអូររាំងឪ ដោយជនជាតិវៀតណាមខាងត្បូង ហើយនិងកងទ័ពថ្មើរជើងអាមេរិកកាំង នៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧០ ដែលគាត់ជឿជាក់ថា បានបណ្តាលឲ្យប្រជាជនខ្មែរ "គ្មានជម្រើស" ក្រៅពីចូលរួមជាមួយនឹងខ្មែរក្រហម។ ការទម្លាក់គ្រាប់បែកលើកទីពីរ បានចាប់ផ្តើមពីថ្ងៃទី៦ ខែកុម្ភៈ ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ហើយជាការទម្លាប់បែកទ្រង់ទ្រាយធំរបស់អាមេរិកកាំងមកលើប្រទេសកម្ពុជា។ សាក្សីបានបញ្ជាក់ថា វាកើតឡើងនៅក្រោយអំឡុងពេល ដែលប្រជាជនមកពីជនបទបានចាប់ផ្តើមភៀសខ្លួនជាក្រុមៗមកកាន់ទីក្រុង ដើម្បីស្វែងរកកន្លែងស្នាក់នៅ និងស្បៀងអាហារ។ គាត់បានប៉ាន់ស្មានថា មកដល់ខែមេសា ឆ្នាំ១៩៧៥ មានប្រជាជនចន្លោះពី ពីរលានទៅបីលាននាក់នៅក្នុងទីក្រុងភ្នំពេញ។ មេធាវី **កូប៉េ** បានចោទសួរសាក្សីពីផលប៉ះពាល់នៃកង្វះស្បៀងអាហារមុនខែមេសា ឆ្នាំ១៩៧៥។ សាក្សី **ប៉ុងសូធ៍** បានឆ្លើយតបវិញថា "នៅក្នុងក្រុង ក៏ដូចនៅតាមជនបទដែរ គឺថាកាលនោះមានកង្វះស្បៀងអាហារគ្រប់ទីកន្លែងតែម្តង" រួមទាំងកង្វះសេវាសុខភាព នៅទូទាំងប្រទេសផងដែរ។

សាក្សី ប៉ុងសូង៍ បានរម្លឹកថា នៅដើមឆ្នាំ១៩៧៣ ខ្មែរក្រហមបានជួយប្រជាជនកម្ពុជាធ្វើស្រែចម្ការ។ គាត់បានជឿជាក់ថា ប្រជាជនកម្ពុជា បានជួយគាំទ្រខ្មែរក្រហម ទោះបីជាបានឮពីការរៀបរាប់អំពើព្រៃផ្សៃ និង "ការអាក្រក់របស់ខ្មែរក្រហម" ក៏ដោយ ព្រោះតែភាពសាហាវព្រៃផ្សៃនៃរបប លន់ នល់ ហើយក្តីសង្ឃឹមរបស់ប្រជាជនបានរំពឹងថា ខ្មែរក្រហមអាចនឹងប្រព្រឹត្តល្អជាងនេះទៅលើពួកគេ។ គាត់ពិតជាបានរម្លឹកពីការឮការរៀបរាប់ពីភាពសាហាវព្រៃផ្សៃ និងអំពើឃោរឃៅរបស់ខ្មែរក្រហម ក្នុងតំបន់រំដោះមួយចំនួន នៅខេត្តកំពង់ធំ និងកំពង់ចាម។ ប្រការនេះ បានរាប់បញ្ចូលពីការជម្លៀសប្រជាជនចេញពីតំបន់ "រំដោះ" ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងការសម្លាប់មន្ត្រីផងដែរ។ ក៏ប៉ុន្តែ ដោយយល់ស្របនឹងប្រជាជនកម្ពុជាជាច្រើន គាត់បានសន្និដ្ឋានថា អំពើទាំងនេះ គឺជាការបង្កើតល្បិចសង្គ្រាមរបស់ខ្មែរក្រហម ហើយប្រហែលអាចបញ្ឈប់នៅពេលទទួលបានជ័យជម្នះ។

### *ខ.២. ព្រឹត្តិការណ៍នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

សាក្សីបាននិយាយថា មុនការដួលរលំទីក្រុងភ្នំពេញ គាត់កំពុងធ្វើការជាមួយនឹងជនភៀសខ្លួន ដើម្បីដាំបន្លែនៅតំបន់ជាយក្រុង។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ គាត់បានឃើញទីក្រុងភ្នំពេញកំពុងតែប្រឈមមុខនឹងការទម្លាក់គ្រាប់បែក និងការបាញ់បោះគ្នាចេញពីគ្រប់ទិស ហើយគាត់បានយល់ថា ខ្មែរក្រហមអាចនឹងឡោមព័ទ្ធទីក្រុងបានទាំងមូលក្នុងពេលឆាប់ៗនេះ។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ គាត់ចាកចេញពីការិយាល័យព្រះវិហារស្រុក ទៅកាន់សណ្ឋាគារលើភ្នំ ដែលត្រូវបានប្រកាសដោយកាកបាទក្រហមថា ជាតំបន់គ្មានយោធា ហើយគាត់បានបម្រើការជាភ្នាក់ងារសម្រាប់ជនភៀសខ្លួនអន្តរជាតិ។ នៅទីនោះ គាត់បានធ្វើការជាអ្នកបកប្រែភាសាខ្មែរ-បារាំង ហើយបានជួយដល់ប្រជាជនគ្មានអាវុធដើម្បីស្នើសុំរកសិទ្ធិជ្រកកោន។ នៅរសៀលថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ គាត់បានរម្លឹកពីការឮសំឡេងវាយប្រហារ និងការបាញ់បោះដាក់គ្នានៅជុំវិញតំបន់ក្បែរទីក្រុងភ្នំពេញ។ នៅខណៈដែលគាត់បានធ្វើដំណើរពីសណ្ឋាគារលើភ្នំ ទៅកាន់ការិយាល័យព្រះវិហារស្រុក គាត់បានឃើញសាកសពមនុស្សចំនួនប្រាំពីរនាក់ ដែលបានស្លាប់ដោយសារតែការបន្ទុះគ្រាប់បែកនៅក្បែរលំនៅដ្ឋានរបស់គាត់។ នៅថ្ងៃបន្ទាប់មក គាត់បានឃើញរថក្រោះកំពុងរំកិលចូលមកក្នុងទីក្រុងភ្នំពេញ ដែលបានបាញ់ផ្លោងទៅវិញទៅមក ហើយបន្ទាប់មកមានទាហាន លន់ នល់ មួយចំនួនបានចុះចាញ់។ គាត់បានកត់សម្គាល់ពីជំនឿភាន់ច្រឡំរបស់ប្រជាជនកម្ពុជា និងអ្នកកាសែតមួយចំនួន ដែលថាទាហានដែលបានចូលមកទីក្រុងភ្នំពេញដំបូងគេនៅថ្ងៃនោះ គឺជាទាហានខ្មែរក្រហម។ តាមពិតទៅ គាត់បានផ្តល់សក្ខីកម្មថា ពលទាហានទាំងអស់នោះ ជាកងទ័ពរបស់ លន់ នល់ ដែលបានសុំចុះចាញ់។ ប្រហែលនៅម៉ោង១០ព្រឹក ខ្មែរក្រហមបានឡោមព័ទ្ធទីក្រុងបានទាំងមូល ហើយទាហាន លន់ នល់ បានបរាជ័យ និងបានលើកទង់សុំចុះចាញ់។ យោងតាមការចងចាំរបស់សាក្សី ការបាញ់បោះបានបញ្ឈប់នៅពេលនោះ ហើយទីក្រុង បានប្រែក្លាយមកជាស្ងប់ស្ងាត់ទាំងស្រុងតែម្តង។

### *ខ.៣. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

នៅពេលព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រហែលជាម៉ោង១១ព្រឹក សាក្សី ប៉ុងសូង៍ បានឃើញដោយផ្ទាល់ភ្នែកនូវ "ទិដ្ឋភាពដែលគាត់មិនអាចបំភ្លេចបាន" គឺឃើញអ្នកជំងឺ អ្នករបួសចេញរាប់រយនាក់ អ្នកខ្លះគ្មានជើង គ្មានដៃ "វារលើដីដូចជន្លេន" កាត់មុខផ្ទះគាត់។[11] នៅពេលដែលមានសំណួរបន្ថែមអំពីព្រឹត្តិការណ៍

នេះពីសំណាក់សហព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល** សាក្សី **ប៉ុងសូដ៍** បានពន្យល់ថា គាត់បានឮពីវេជ្ជបណ្ឌិតម្នាក់ថា អ្នកជំងឺ និងជនពិការក្នុងមន្ទីរពេទ្យ នឹងត្រូវយកទៅសម្លាប់ ប្រសិនបើពួកគេបដិសេធមិនចាកចេញពីមន្ទីរពេទ្យ។ គាត់បានផ្តល់សក្ខីកម្មបន្ថែមថា គាត់មានអារម្មណ៍ថា “ខ្មាស” ខ្លួនឯង ដោយបានបដិសេធក្នុងការអនុញ្ញាតឲ្យបុរសពិការម្នាក់ជ្រកកោនជាមួយនឹងគាត់ ទោះជាយ៉ាងណាក្តី សាក្សី **ប៉ុងសូដ៍** បានបដិសេធនេះ ដោយសារតែការភ័យខ្លាចថា រូបគាត់ និងបុរសពិការនោះ ប្រហែលជាអាចនឹងយកទៅសម្លាប់ ប្រសិនបើពួកខ្មែរក្រហមរកឃើញ។ ប្រហែលជាថ្ងៃត្រង់ គាត់បានឮថា មានក្រុមជាក់លាក់ជាច្រើនជាពិសេស ជនជាតិចាមត្រូវបានគេបណ្តេញចេញពីទីក្រុង។

យោងតាមការចងចាំរបស់សាក្សី នៅប្រហែលជាម៉ោង២រសៀល ទាហានខ្មែរក្រហមដែលមានសំលៀកបំពាក់ពណ៌ខ្មៅ បានប្រកាសថា ប្រជាជនទាំងត្រូវតែចាកចេញពីទីក្រុង ដោយហេតុថា អាមេរិកកាំងនឹងទម្លាក់គ្រាប់បែកមកលើទីក្រុងភ្នំពេញ។ ទាហានខ្មែរក្រហម ក៏បានសុំឲ្យអ្នករស់នៅទីក្រុងទាំងអស់ មិនឲ្យយករបស់របរអ្វីមកជាមួយពួកគេទេ ដោយសារតែពួកគេនឹងត្រឡប់មកទីក្រុងវិញក្នុងអំឡុងពេលបី ឬបួនថ្ងៃក្រោយ។ សាក្សីបានជឿថា ដោយសារតែប្រជាជនជាច្រើនដែលមកពីបណ្តាខេត្តនានា បានចូលមកទីក្រុង ដើម្បីរត់គេចពីការទម្លាក់គ្រាប់បែកនោះ ហេតុនេះហើយ បានធ្វើឲ្យពួកគេជឿជាក់ថា ពួកគេត្រូវតែចាកចេញពីទីក្រុងដើម្បីរត់គេចពីការទម្លាក់គ្រាប់បែកពីសំណាក់អាមេរិកកាំង បន្ថែមទៀត។ សាក្សី **ប៉ុងសូដ៍** បានរៀបរាប់ពីការមើលឃើញមនុស្សប្រហែល២០០ ទៅ៣០០នាក់ បានដើរយឺតៗតាមមហាវិថីព្រះមុនីវង្ស ចេញពីទីក្រុង។ នៅប្រហែលជាម៉ោង៦ល្ងាច សាក្សីមិនបានឃើញប្រជាជនស៊ីវិល នៅក្នុងទីក្រុងភ្នំពេញ ច្រើននោះទេ។ នៅព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ សាក្សី **ប៉ុងសូដ៍** បានដឹកទាហានខ្មែរក្រហមមួយក្រុម (មានគ្នាដប់នាក់) ដែលបានស្នាក់នៅពេលយប់ក្នុងផ្ទះរបស់គាត់នោះ ទៅកាន់ស្ថានីយរថភ្លើង។ នៅតាមផ្លូវ ទាហានខ្មែរក្រហមបានកម្ទេចទ្វារផ្ទះ និងបានយកទ្រព្យសម្បត្តិ ដែលពួកគេបានប្រទះឃើញនៅហ្នឹងកន្លែងនោះតែម្តង។

ជាការឆ្លើយតបទៅនឹងសំណួររបស់មេធាវី **វ៉េកគែន** សាក្សី **ប៉ុងសូដ៍** បានពន្យល់បន្ថែមពីជំនឿរបស់គាត់យ៉ាងពិស្តារថា ការជម្លៀសប្រជាជន គឺមិនគ្រាន់តែជាអំពើសងសឹកសម្រាប់កសិករក្រីក្រ មកលើអ្នកទីក្រុងនោះទេ តែថែមទាំងជាការជំរុញលើកទឹកចិត្ត ដោយមានគំនិតកសាងសង្គមថ្មីមួយដែលគ្មានទីក្រុងផងដែរ។ ថ្វីបើគាត់បានបញ្ជាក់ថា មានបញ្ហាជាច្រើនទាក់ទងនឹងការផ្គត់ផ្គង់ស្បៀងអាហារឲ្យប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលពួកគេទាំងនោះបានធ្វើបន្លាស់ទីពីទីជនបទចូលមកទីក្រុងភ្នំពេញក៏ដោយ ក៏គាត់ហាក់ដូចជាមិនអាចផ្តល់មតិយោបល់ថា ប្រការខាងលើនេះ គឺជាមូលហេតុចម្បង ដែលបណ្តាលឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុង ឬអត់នោះទេ។ គាត់បានសង្កត់ធ្ងន់ថា “មូលហេតុពិតប្រាកដនោះ គឺជាមនោគមន៍វិជ្ជា”។[12] នៅពេលដែលមានសំណួរសួរថា តើខ្មែរក្រហមបានប្រព្រឹត្តយ៉ាងដូចម្តេចមកលើប្រជាជន ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញ? សាក្សី **ប៉ុងសូដ៍** បានបញ្ជាក់ថា ប្រជាជនស៊ីវិល បានបង្ហាញពីភាពភ័យខ្លាច និងទុក្ខសោក ក្នុងការចាកចេញពីទីក្រុង ក៏ប៉ុន្តែគាត់មិនបានឃើញដោយផ្ទាល់ភ្នែកនូវការប្រព្រឹត្តិអំពើធ្វើទុក្ខបុកម្នេញណាមួយ មកលើប្រជាជនទាំងនោះឡើយ។ គាត់បានកត់សម្គាល់ថា ខ្មែរក្រហមមិនចាំបាច់ប្រើប្រាស់ការបង្ខិតបង្ខំដោយកម្លាំងបាយមកលើប្រជាជនស៊ីវិលឡើយ គ្រាន់តែការបង្ខំខាងចិត្តសាស្ត្រ ហើយ “ខ្សែភ្នែកដ៏កាចសាហាវ” របស់ពួកវា ក៏អាចគ្រប់គ្រាន់នឹងបង្ខំឲ្យប្រជាជនស្តាប់តាមបញ្ជាដែរ។

### ខ.៤. អំឡុងពេលនៃការជ្រកកោនក្នុងស្ថានទូតបារាំង

ក្រោយពីបានរៀបរាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមក សាក្សី **ប៉ុងសូដ៍** បានរ៉ាយរ៉ាប់ពីពេលវេលាដែលគាត់បានជ្រកកោនក្នុងស្ថានទូតបារាំង ដែលនៅទីនោះ គាត់បានស្នាក់នៅជាមួយនឹងជនជាតិបរទេសចំនួន ៥០០នាក់ផ្សេងទៀត រួមទាំងជនជាតិអាមេរិកកាំងផងដែរ ហើយខ្លះ គាត់បានដឹងថា ជាភ្នាក់ងារ **ស៊ី.អាយ.អេ** ជាជនជាតិវៀតណាមខាងត្បូង ជនជាតិបារាំង និងជនជាតិឡាវ។ តាមឲ្យដឹងមក មានប្រជាជនកម្ពុជា ៥០០នាក់ ផ្សេងទៀត ដែលបានស្នាក់នៅក្នុងស្ថានទូតបារាំង រួមបញ្ចូលទាំងកងទ័ពនៃរបបមុន (របប លន់ នល់) ផងដែរ។ យោងតាមសាក្សី **ប៉ុងសូដ៍** មានជនជាតិ ប៉ាគីស្ថាន ចំនួន ៥០០នាក់ផ្សេងទៀត បានមកដល់ស្ថានទូតនៅពេលបន្ទាប់។ ជាការឆ្លើយតបទៅនឹងសំណួរពីសំណាក់មេធាវី **វែកគែន** ស្ដីពីឃោសនាការ និងការគោរពក្រមសីលធម៌យ៉ាងពេញលេញក្នុងជួរកងទ័ពខ្មែរក្រហម សាក្សី **ប៉ុងសូដ៍** បានផ្តល់សក្ខីកម្មថា ខ្មែរក្រហមបានគោរពមាគ៌ាសីលធម៌យ៉ាងខ្ជាប់ខ្ជួន។ គាត់បានរម្លឹកពីការឃើញកម្មាភិបាលក្មេងៗរបស់ខ្មែរក្រហម ដែលមានអាយុ១៣ ឬ១៤ឆ្នាំ កំពុងឃ្លាំមើលស្ថានទូតបារាំង បានសូត្រទន្ទេញសីលធម៌ទាំងដប់ពីរប្រការរបស់ខ្មែរក្រហម ជារៀងរាល់ពេលព្រឹក។

សាក្សី **ប៉ុងសូដ៍** បាននិយាយរម្លឹកពីក្រុមមនុស្សពីរក្រុម ដែលត្រូវបានបង្ខំឲ្យចាកចេញពីស្ថានទូត។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធ អាកា៤៧ (AK47) ពេញដៃ ហើយបានទាមទារថា ស្ថានទូតបារាំងត្រូវតែប្រគល់ខ្លួន “មហាជនក្បត់ទាំងប្រាំពីរនាក់” មក។ នៅថ្ងៃបន្ទាប់មក មានបុរសៗជនជាតិកម្ពុជាចំនួន២៥នាក់ ដែលបានរៀបការជាមួយនឹងស្ត្រីជនជាតិបារាំង ត្រូវបានបង្ខំឲ្យចាកចេញពីស្ថានទូត (ក៏ប៉ុន្តែ ស្ត្រីជនជាតិកម្ពុជា ដែលបានរៀបការជាមួយនឹងបុរសជនជាតិបារាំង ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅបន្ត)។ ជាការឆ្លើយតបទៅនឹងការជជីកសួរពីសំណាក់សហព្រះរាជអាជ្ញា **ចាន់ តារាស្មី** សាក្សី **ប៉ុងសូដ៍** បាននិយាយថា តាមដែលគាត់ចងចាំកន្លងមក គ្មាននរណាម្នាក់ត្រូវបានបង្ខំឲ្យចាកចេញដោយការផ្ជង់កាំភ្លើងដាក់ឡើយ។ ក៏ប៉ុន្តែ គាត់បានបន្ថែមថា ប្រជាជនមានភាពភ័យខ្លាចយ៉ាងខ្លាំងថា ពួកគេអាចនឹងធ្វើអ្វីគ្រប់យ៉ាង តាមតែខ្មែរក្រហមសុំ។ គាត់បាននិយាយថា គាត់មិនដឹងថា មានអ្វីកើតឡើងចំពោះប្រជាជនទាំងនោះទេ ក៏ប៉ុន្តែ នៅពេលក្រោយមក គាត់បានដឹងថា ពួកគេអាចត្រូវបានយកទៅសម្លាប់ ឬត្រូវបានបញ្ជូនទៅព្រំដែន។ គាត់ក៏បាននិយាយរម្លឹកផងដែរ ពីការយល់ដឹងតាមគីមីវិទូខ្មែរម្នាក់ថា មានប្រជាជនមួយចំនួនត្រូវបានបញ្ជូនទៅកាន់ស្ពាតចាស់ ហើយបានបន្តដំណើរទៅមុខទៀត ដោយចែកជាបីក្រុមៈ បុគ្គលិកយោធា មន្ត្រីស៊ីវិល និងប្រជាជនដទៃទៀត។ បន្ទាប់មក ចំពោះមន្ត្រី និងរដ្ឋការដែលមានឋានន្តរស័ក្តិជាន់ខ្ពស់ ត្រូវបានដឹកជញ្ជូនចេញតាមឡានធំ។

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៥ ដោយស្ថិតនៅក្នុងក្រុមទីពីរសម្រាប់ការធ្វើដំណើរចាកចេញពីស្ថានទូតបារាំង សាក្សី **ប៉ុងសូដ៍** ត្រូវដឹកចេញតាមរថយន្តធំ ដែលបើកបរដោយខ្មែរក្រហមទៅកាន់ព្រំដែនកម្ពុជា និងថៃ តាមផ្លូវជាតិលេខ ៤ កាត់ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង ឆ្ពោះទៅកាន់ព្រំដែនប៉ោយប៉ែត។ សាក្សី **ប៉ុងសូដ៍** បាននិយាយរម្លឹកពីអ្វីដែលគាត់បានប្រាប់ខ្មែរក្រហមថា គាត់មិនចង់ចាកចេញនោះទេ ហើយគាត់សុំ “រស់នៅក្នុងប្រទេសកម្ពុជារហូតដល់ថ្ងៃ ដែលគាត់ស្លាប់តែម្តង”។ ខ្មែរក្រហមបានប្រាប់គាត់វិញថា ពួកគេមិនអាចទទួលខុសត្រូវចំពោះសុវត្ថិភាពរបស់គាត់បាននោះទេ ហើយពួកគេនិយាយថា នៅពេលណាដែលប្រទេសជាតិ ត្រូវបាន “បោសសម្អាត” រួចរាល់ហើយ គាត់នឹងអាចវិលត្រឡប់មកវិញដោយក្តី

ស្វាគមន៍យ៉ាងកក់ក្ដៅពីពួកគេ។ សាក្សី **ប៉ុងសូដ៍** បានផ្ដល់សក្ខីកម្មថា នៅពេលនោះ គាត់បានយល់យ៉ាងច្បាស់រួចជាស្រេចនូវឃ្លា "បោសសម្អាតទីក្រុង និងប្រទេស" ដែលមានន័យថា ជាការបោសសម្អាតមន្ត្រីនៃរបបមុន (របប **លន់ នល់**) ចេញពីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ គាត់បានរម្លឹកពីភាពងាយស្រួលក្នុងការចាកចេញពីប្រទេស ហើយគាត់បានផ្ដល់យោបល់ថា ខ្មែរក្រហម "គួរសម" ណាស់នឹងជនបរទេស។ ក្នុងអំឡុងពេលធ្វើដំណើរទៅកាន់ព្រំដែន គាត់បានឃើញផ្សែង និងភ្លើងឆេះចេញពីទីវាលស្រែ និងភូមិប្រជាជន ក៏ប៉ុន្តែគាត់មានការភ្ញាក់ផ្អើលណាស់ ដោយមិនបានឃើញប្រជាជនកម្ពុជា សូម្បីតែម្នាក់ នៅតាមផ្លូវដែលគាត់បានឆ្លងកាត់មកនោះ។

## *ខ.៥. កំណត់ហេតុបានមកពីជនភៀសខ្លួនកម្ពុជា និងវិទ្យុកម្ពុជាប្រជាធិបតេយ្យ*

នៅក្រោយពេលដែលបានចាកចេញពីប្រទេសកម្ពុជា សាក្សី **ប៉ុងសូដ៍** បានធ្វើការសម្ភាសន៍ចំនួន៩៤លើក ជាមួយនឹងជនភៀសខ្លួនកម្ពុជានៅតាមព្រំដែនថៃ ហើយក្រោយមកទៀត ក្នុងប្រទេសបារាំងនៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦។ បទសម្ភាសន៍ទាំងនេះ គឺជាមូលដ្ឋានសម្រាប់ការសរសេរសៀវភៅរបស់គាត់ ដែលមានចំណងជើងថា "ប្រទេសកម្ពុជា៖ ឆ្នាំសូន្យ"។ នៅក្នុងសក្ខីកម្មរបស់គាត់ គាត់បានរ៉ាយរ៉ាប់ពីការស្ដាប់នូវរឿងរ៉ាវពីជនភៀសខ្លួនចំនួនបួននាក់ ដែលបានធ្វើបទសម្ភាសន៍ ដោយពួកគេបានអះអាងថា បានរួចជីវិតពីការសម្លាប់ទាហាន ៣៨០នាក់ នៅភ្នំធិបតី នៅក្រោយពេលខ្មែរក្រហមបានបោកក្រុមទាហាននោះឲ្យទៅកាន់ភ្នំធិបតី ហើយបន្ទាប់មកបានបាញ់រះសម្លាប់ពួកគេតែម្ដង។ សាក្សីរូបនេះ បានជឿជាក់ថា កំណត់ហេតុទាំងនេះពិតប្រាកដមែន ដោយសារតែមានសាក្សីពីរនាក់ក្នុងចំណោមបួននាក់ដែលគាត់បានសម្ភាសន៍នោះ បានរាយការណ៍ពីការដើរឆ្លងកាត់តំបន់ជាច្រើន ហើយបានឃើញសាកសព និងគ្រោងឆ្អឹងមនុស្សជាច្រើននៅពេលខុសៗគ្នា។ គាត់ក៏បានលើកឡើងផងដែរ នូវសេចក្ដីថ្លែងការណ៍ដែលបានធ្វើឡើងដោយជនភៀសខ្លួនស្ដីពី "គុកដែលគ្មានជញ្ជាំង" ដែលជាទីកន្លែងប្រជាជន "ធ្វើការទាំងថ្ងៃទាំងយប់ ដោយមិនខ្លាចនឿយហត់ និងទុក្ខលំបាក"។[13] គាត់បានបន្ថែមថា ខ្មែរក្រហមបានចាត់ទុកទីកន្លែងទាំងនោះថា ជា "ការរដ្ឋាន"។

ក្នុងបទសម្ភាសន៍មួយផ្សេងទៀត ដែលសាក្សី **ប៉ុងសូដ៍** បានធ្វើឡើងនៅក្នុងជំរំភៀសខ្លួនមួយ កាលពីឆ្នាំ១៩៧៦ ជាមួយនឹងអតីតអ្នកបើកឧទ្ធម្ភាគចក្រម្នាក់ គឺវរសេនីយ៍ឯក **ពេជ្រ លឹមគួន** ដែលគាត់បានរ៉ាយរ៉ាប់ពីការដឹកមេដឹកនាំខ្មែរក្រហមចំនួនប្រាំនាក់ ក្នុងនោះមានលោក **ខៀវ សំផន** ឬហៅថា "សមមិត្ត **ហែម**" ផងដែរ។ មេធាវី **វែកគែន** បានតទល់នឹងភាពត្រឹមត្រូវនៃបទសម្ភាសន៍នោះ ដោយបានដកស្រង់នូវបទសម្ភាសន៍លើកទីពីរ ដែលបានធ្វើឡើងដោយឯករដ្ឋទូតបារាំងក្នុងឆ្នាំ១៩៧៦ ដែលវរសេនីយ៍ឯក **គួន** បាននិយាយថា លោក **ខៀវ សំផន** "មិនមែនស្ថិតនៅក្នុងចំណោមក្រុមអ្នកដឹកនាំជាន់ខ្ពស់នោះទេ"។ ប្រការបែបនេះ បាននាំឲ្យឯករដ្ឋទូតរូបនោះធ្វើការសន្និដ្ឋានថា មុខតំណែងរបស់លោក **ខៀវ សំផន** ដែលជាប្រធានរដ្ឋនោះ គឺគ្រាន់តែជាកិត្តិយសធម្មតាមួយតែប៉ុណ្ណោះ។ សាក្សី បានរៀបរាប់ឡើងវិញដោយសាមញ្ញថា ព័ត៌មានដែលវរសេនីយ៍ឯក **គួន** បានផ្ដល់ឲ្យគាត់ គឺគ្រាន់តែថា លោក **ខៀវ សំផន** គឺជាអ្នកដឹកនាំមួយរូប ក្នុងចំណោមមេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ហើយថាគាត់បានស្គាល់ឈ្មោះ សមមិត្ត **ហែម** ហ្នឹង តាមរយៈឈ្មោះ **គួន** នេះ។

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនលើកទីពីរ សាក្សីបាននិយាយថា កំណត់ហេតុរបស់ជនភៀសខ្លួនបានឆ្លុះបញ្ចាំងពីអំពើប្រព្រឹត្តិដ៏ឃោរឃៅកាន់តែខ្លាំងឡើងៗ។ ដោយប្រៀបប្រដូចស្ថានភាពទាំងនេះទៅនឹងអំពើប្រព្រឹត្តិមកលើជនជាតិ យូដា (Jews) ដោយពួកណាហ្ស៊ី ក្នុងប្រទេសអាឡឺម៉ង់ សាក្សី ប៉ុងសូដ៏ និយាយថា ប្រជាជនខ្មែរត្រូវបានដឹកដោយរថភ្លើងពីខេត្តតាកែវ ទៅកាន់ទីក្រុងភ្នំពេញ ហើយបន្ទាប់មក ទៅតាមផ្លូវទៅកាន់ភ្នំធិបតី ដោយបានញាត់ពួកគេក្នុងទូរថភ្លើងពោរពេញដោយមនុស្ស ដោយគ្មានស្បៀងអាហារបរិភោគ គ្មានទឹកផឹក ហើយនិងគ្មានទីកន្លែងឲ្យពួកគេសម្រាប់បន្ទោបង់ឡើយ។

យោងតាមសាក្សី ប៉ុងសូដ៏ ដំបូងឡើយ គាត់មិនជឿលើកំណត់ហេតុរបស់ជនភៀសខ្លួនទាំងនោះឡើយ ដោយសារតែពួកគេបានរៀបរាប់ថា ពួកគេបានធ្វើការទាំងថ្ងៃទាំងយប់ ដែលប្រការនេះ “ពិបាកជឿ គឺហួសពីជឿទៅទៀត”។[14] គាត់បានចាប់ផ្តើមស្តាប់ការផ្សព្វផ្សាយវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងគោលបំណងទទួលយកនូវព័ត៌មាន ដែលកំពុងកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។ គាត់បានរម្លឹកពីការឮពាក្យស្លោកតាមរយៈការផ្សព្វផ្សាយវិទ្យុដែលបានប្រកាសថា “ទុកក៏មិនចំណេញ ដកចេញក៏មិនខាត” “សម្លាប់ច្រឡំ ប៉ុន្តែកុំលែងច្រឡំ” “គឺថាត្រូវតែកម្ទេចរបប ត្រូវតែកម្ទេចខ្មាំង យើងត្រូវតែកាត់សាច់ណាដែលស្អុយចោល អ្វីដែលវែងពេកត្រូវតែបង្រួញឲ្យខ្លី យើងកាត់តែរុក្ខជាតិណាដែលមិនល្អមិនបានទេ ត្រូវបោច -- ដកស្មៅត្រូវតែដកទាំងឫសតែម្តង”។[15] នៅពេលមានសំណួរសួរដោយសហព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល** ថា គាត់បានគិតយ៉ាងម៉េចចំពោះអត្ថន័យនៃពាក្យស្លោកទាំងនេះ សាក្សី **ប៉ុងសូដ៏** ក៏បាននិយាយថា ពាក្យស្លោកទាំងនេះ គឺចេញមកពីគំនិតរបស់អង្គការ ដែលថា ប្រជាជនត្រូវតែបរិសុទ្ធ អត់មានគំនិតផ្ទាល់ខ្លួននោះទេ ហើយពួកគេត្រូវតែបូជាខ្លួនឯងទៅតាមអង្គការ និងដើម្បីផលប្រយោជន៍ប្រទេសជាតិ តែប៉ុណ្ណោះ។ គាត់បានកត់សម្គាល់ថា ភាសាដែលអង្គការបានប្រើប្រាស់ គឺមានលក្ខណៈខុសប្លែកពីពេលមុនៗ ហើយប្រជាជនត្រូវតែស្វែងយល់ពីរបៀបនៃការនិយាយថ្មីនេះ ដើម្បីជៀសវាងកុំឲ្យគេកម្ទេចចោល។

ក្នុងសក្ខីកម្មបន្ថែមស្តីពីបទសម្ភាសន៍ដែលគាត់បានធ្វើ សាក្សី **ប៉ុងសូដ៏** បានរាយការណ៍ពីការឮនូវរឿងរ៉ាវពីព្រះសង្ឃជាច្រើនអង្គ ដែលត្រូវបានខ្មែរក្រហមបង្ខំចាប់ផ្សឹក ហើយនិងកំណត់ហេតុពីស្ត្រីជាច្រើននាក់ ដែលបានធ្វើអត្តឃាតខ្លួនឯង នៅក្រោយពេលដែលខ្មែរក្រហមបង្ខំឲ្យរៀបការជាមួយនឹងទាហានខ្មែរក្រហមដែលជាជនពិការ។ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត (Elisabeth Simonneau-Fort)** បានចោទសំណួរទៅកាន់សាក្សី **ប៉ុងសូដ៏** ស្តីពីអត្ថបទជាច្រើន ដែលគាត់បានសរសេរឲ្យទស្សនាវដ្តីបារាំងមួយឈ្មោះ **ឡឺម៉ុងដ៍** ក្នុងឆ្នាំ១៩៧៦ ស្តីពីការបែកចែករវាង “ប្រជាជនចាស់” (ប្រជាជនដែលបានរំដោះមុនឆ្នាំ១៩៧៥) និង “ប្រជាជនថ្មី” (ប្រជាជនដែលបានរំដោះនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥) ដែលពួកគេត្រូវបានចាត់ទុកថា ជា “អ្នកទោសសង្គ្រាម គ្មានសិទ្ធិធ្វើអ្វីទាំងអស់”។ សាក្សី **ប៉ុងសូដ៏** បានផ្តល់សក្ខីកម្មថា ការរៀបរាប់របស់គាត់ស្តីពីការបែងចែកប្រជាជននេះ គឺផ្អែកតាមកំណត់ហេតុ ដែលបានទទួលពីជនភៀសខ្លួន។[16]

មេធាវី **វែកគែន** បានសួរដេញដោលសាក្សី ស្តីពីឯកសារដែលគាត់បានផ្ញើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលគាត់បានរៀបរាប់ពីការមិនបានឮ “អ្វីទាល់តែសោះ” តាមរយៈវិទ្យុកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធនឹងលោក **ខៀវ សំផន**។ សាក្សី **ប៉ុងសូដ៏** បានបញ្ជាក់លើបញ្ហានេះ ហើយបានបន្ថែមថា លោក **ខៀវ សំផន** មិនមែនជាបងធំមានលេខអីហ្នឹងគេនោះទេ។ តាមពិត យោងតាមសក្ខីកម្មរបស់សាក្សី លោក

**ខៀវ សំផន** “គឺមានលេខរៀងនៅពីក្រោយលោក **អៀង សារី**” ទៅទៀត។[17] មេធាវី **វែកគែន** ក៏បានព្យាយាមចោទសួរដេញដោលសាក្សីឲ្យពន្យល់ថា តើការប្រព្រឹត្តិ និងការសម្លាប់យ៉ាងព្រងើយកន្តើយ មកលើជនភៀសខ្លួនកម្ពុជា ពីសំណាក់អាជ្ញាធរថៃ ជាមូលហេតុដែលអាចជះឥទ្ធិពលដល់កំណត់ហេតុរបស់ជនភៀសខ្លួនទាំងនោះ នៅពេលដែលគាត់បានចងក្រងឯកសារដែរ ឬទេ? សាក្សី **ប៉ុងសូជ៍** បានឆ្លើយតបថា ទោះបីជាធ្វើការពិចារណាទៅលើបរិបទនយោបាយរបស់ជនភៀសខ្លួនទាំងនោះក៏ដោយ ក៏គាត់បានជឿជាក់ថា ពួកគេបានកំពុងប្រាប់គាត់ពីការពិត។ សាក្សីបានបដិសេធចំពោះការចោទប្រកាន់ ដែលបានធ្វើឡើងដោយលោក **ហ្គារ៉ែត ព័រទ័រ** (Gareth Porter) ដោយនិយាយថា ជនភៀសខ្លួនទាំងនោះ គឺជាអ្នកដែលព្យាយាមទម្លាក់កំហុសមកលើរបបនោះ។ យោងតាមសាក្សី **ប៉ុងសូជ៍** បានឲ្យដឹងថា គាត់បានប្រើប្រាស់ “ទម្រង់វិទ្យាសាស្ត្រដើម្បីរកភស្តុតាង” [18] ដោយស្តាប់យ៉ាងយកចិត្តទុកដាក់ និងប្រយ័ត្នប្រយែងបំផុតក្នុងការទាញយករឿងរ៉ាវរបស់ជនភៀសខ្លួនទាំងនោះ ស្របពេលដែលគាត់បានស្តាប់ការផ្សព្វផ្សាយតាមវិទ្យុផងដែរ ដើម្បីធ្វើការផ្ទៀងផ្ទាត់ទៅនឹងរឿងរ៉ាវទាំងនោះ។ នៅពេលមេធាវី **វែកគែន** ធ្វើការសង្កត់សួរបន្ថែម សាក្សី **ប៉ុងសូជ៍** បានអះអាងថា សេចក្តីណែនាំជាទូទៅដែលចេញដោយខ្មែរក្រហម ជួនកាល ត្រូវបានយកមកអនុវត្តដោយភាពងងឹតងងុល ដោយកម្មាភិបាលតូចតាចដែលរបបមុនមិនបានអើពើពួកគេទាល់តែសោះ។ នៅក្នុងស្ថានភាពទាំងនេះ សាក្សី **ប៉ុងសូជ៍** បញ្ជាក់ថា គាត់ជឿជាក់ថា ប្រធានសហករណ៍ គឺជា “អ្នកដែលសម្លាប់មនុស្សយ៉ាងពិតប្រាកដនោះ” គឺពួកគេ “បានបញ្ជូនមនុស្សទៅឲ្យថ្នាក់លើ គឺដូចជា បញ្ជូនទៅគណៈឃុំ ឬគណៈតំបន់។ល។ ដើម្បីឲ្យគេសម្លាប់”។[19]

ដូចគ្នាទៅនឹងមេធាវី **វែកគែន** ផងដែរ មេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** លោក **វ៉ិចទ័រ កូប៉េ** បានតទល់ប្រឆាំងនឹងប្រត្យក្សភាព (ភាពត្រឹមត្រូវ) នៃបទសម្ភាសន៍របស់សាក្សី។ មេធាវីការពារក្តី បានដកស្រង់ការរិះគន់របស់ **ម៉ៃខល វីកឃើរី** (Michael Vickery) ដែលថា ការជ្រើសរើសធ្វើកិច្ចសម្ភាសន៍ បានបញ្ជូនព័ត៌មានពីវណ្ណៈកសិករមានតិចតួចបំផុត ព្រមទាំងបរាជ័យ ក្នុងការពិចារណាលើការបកស្រាយពីភាពខុសៗគ្នា ចំពោះសេចក្តីបង្គាប់បញ្ជារបស់អង្គការលើវិស័យផ្សេងៗក្នុងប្រទេសកម្ពុជា។ សាក្សី **ប៉ុងសូជ៍** បានការពារការជ្រើសរើសធ្វើបទសម្ភាសន៍របស់គាត់យ៉ាងខ្លាំងក្លា ដោយបញ្ជាក់ថា ជនភៀសខ្លួនត្រូវបានជ្រើសរើសធ្វើបទសម្ភាសន៍ដោយចៃដន្យ។ គាត់បានសន្មតពីចំនួនតិចតួចនៃបទសម្ភាសន៍ ដែលបានមកពីកសិករ ដោយហេតុផលថា ជនភៀសខ្លួនបានមកដល់ជំរំជាក្រុមៗ មានដូចជា ដំបូងគេ គឺក្រុមអ្នករស់នៅក្នុងទីក្រុង និងទាហាន បន្ទាប់មក គឺក្រុមជនជាតិចិន ហើយបន្តបន្ទាប់មក គឺក្រុមគ្រូបង្រៀន និងព្រះសង្ឃ ក្រុមបញ្ញវន្ត ហើយក្រុមចុងក្រោយគេ គឺក្រុមកសិករ។ គាត់បានក្រើនរម្លឹកដល់អង្គជំនុំជម្រះថា មនោគមវិជ្ជាដែលនៅពីក្រោយបដិវត្តន៍នោះ គឺជាការការពារ និងការផ្គត់ផ្គង់ដល់វណ្ណៈកសិករ។ ហេតុដូច្នោះហើយ នៅពេលដែលសៀវភៅរបស់គាត់បានបោះពុម្ពផ្សាយ វណ្ណៈកសិករនៅមិនទាន់ស្ថិតនៅក្នុងក្រុមជនភៀសខ្លួននៅឡើយទេ។ ទាក់ទងនឹងការរិះគន់ដែលថា គាត់មាននិន្នាការនិយាយជាលក្ខណៈទូទៅពេក ចំពោះការប្រព្រឹត្តិទៅលើប្រជាជនក្នុងខេត្តបាត់ដំបង និងទីក្រុងភ្នំពេញ ដោយបានសន្មតថា ជាការប្រព្រឹត្តិទៅលើប្រទេសកម្ពុជាទាំងមូល។ សាក្សី **ប៉ុងសូជ៍** បានទទួលស្គាល់ថា សៀវភៅរបស់គាត់ផ្អែកលើព័ត៌មាន ដែលអាចរកបានមុនឆ្នាំ ១៩៧៦ ចំណែកឯអ្នករិះគន់ អាចទាញពីភាពខុសគ្នារវាងផ្នែកនីមួយៗ ដោយផ្អែកលើព័ត៌មានដែលប្រមូលបាន នៅពេលក្រោយមក។

មេធាវី គូប៉េ បានបញ្ចប់ការតាំងសំណួររបស់គាត់ ដោយព្យាយាមចោទសួរសាក្សីអំពីសេចក្តីថ្លែងការណ៍ ដែលគាត់ធ្លាប់បានធ្វើឲ្យខាងការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីពេលមុន ដោយបានរៀបរាប់ពីការសម្លាប់ជនជាតិវៀតណាមចំនួន ២០០០នាក់ ដោយទាហាន លន់ នល់ ហើយត្រូវបានចាត់ទុកថាជា "អំពើប្រល័យពូជសាសន៍" ក៏ប៉ុន្តែគាត់បានប្រានចោលយ៉ាងច្បាស់ ចំពោះការប្រើប្រាស់ពាក្យពេចន៍ដែលសំដៅដល់ការប្រព្រឹត្តិរបស់ខ្មែរក្រហមមកលើអ្នកកាន់សាសនាគ្រិស្ត អ្នកកាន់សាសនាព្រះពុទ្ធ និងជនជាតិចាម។ សាក្សី ប៉ុងសូដ៍ បានឆ្លើយតបមកវិញថា គាត់បានជឿថា ជនជាតិវៀតណាម ត្រូវបានគេធ្វើទុក្ខបុកម្នេញនៅពេលនោះ ដោយសារតែពួកគេជា "យួន" រីឯអ្នកកាន់សាសនាគ្រិស្ត និងអ្នកកាន់សាសនាព្រះពុទ្ធមិនត្រូវបានគេ "ធ្វើទុក្ខបុកម្នេញ" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ក៏ប៉ុន្តែពួកគេជាច្រើនបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទាក់ទិននឹងជនជាតិចាម គាត់បាននិយាយថា "ចាមមិនត្រូវបានធ្វើទុក្ខបុកម្នេញអ្វីនោះទេ រហូតដល់ឆ្នាំ១៩៧៨ ក្រោយមកខុសគ្នា គឺតាមសម្លាប់ចាម"។[20]

### ខ.៦. ឥរិយាបថ និងភាពគួរឲ្យជឿជាក់របស់សាក្សី

ទោះបីជាសាក្សីហាក់ដូចជាគួរឲ្យជឿជាក់ និងមានភាពស៊ីគ្នា ក្នុងការផ្តល់ព័ត៌មានយ៉ាងលម្អិតពីអង្គហេតុយ៉ាងណាក៏ដោយ ក៏នៅមានពេលខ្លះ សាក្សីមិនបានឆ្លើយតបទៅនឹងសំណួរ ឬបែរជាផ្តល់នូវការវិភាគដ៏វែងអន្លាយពីប្រវត្តិសាស្ត្រ និងបរិបទ ដែលមិនមានភាពពាក់ព័ន្ធគ្នាអ្វីឡើយ។ មានឱកាសជាច្រើនក្នុងអំឡុងពេលបីថ្ងៃដែលគាត់បានផ្តល់សក្ខីកម្ម អង្គជំនុំជម្រះបានសួរកាត់សម្តីសាក្សី ហើយមេធាវីប្រឹក្សាក្តី ត្រូវតែក្រើនរម្លឹកដល់គាត់ឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់ ហើយមិនឲ្យបន្ថែមបញ្ហាទាំងឡាយណា ដែលមិនជាប់ពាក់ព័ន្ធឡើយ។ សាក្សីក៏បានធ្វើការបញ្ជាក់នូវបំណង ដែលមានជាយូរមកហើយ ក្នុងការផ្តល់នូវមតិយោបល់តាមរយៈសក្ខីកម្មរបស់គាត់ផងដែរ។ នៅថ្ងៃចុងក្រោយនៃការចោទសួរដេញដោលសាក្សី ប្រការបែបនេះ បានបញ្ចប់តាមសំណើរបស់គាត់ចំពោះការស្នើសុំការអនុញ្ញាតឲ្យ "ផ្តល់ជាគំនិតខ្លះៗ" ទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទ **ខៀវ សំផន** ។ លោកប្រធានអង្គជំនុំជម្រះ បានបដិសេធភ្លាមៗ មិនអនុញ្ញាតឲ្យសាក្សីធ្វើការបកស្រាយលម្អិតលើប្រធានបទនេះឡើយ។[21]

## ផ្នែកទី ៣ៈ បញ្ហាច្បាប់ និងនីតិវិធី

នាសប្តាហ៍នេះ បញ្ហាច្បាប់ និងនីតិវិធីជាច្រើនដែលធ្លាប់បានកើតឡើងកន្លងមក បានកើតឡើងសាជាថ្មីម្តងទៀត ជាពិសេសទាក់ទងនឹងភស្តុតាងជាពាក្យចចាមអារ៉ាម មតិយោបល់ ឬការសន្និដ្ឋានរបស់សាក្សី ហើយនិងការតាំងសំណួរ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១។ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី **នោម សែ** អង្គជំនុំជម្រះក៏បានក្រើនរម្លឹកជាថ្មីម្តងទៀតផងដែរ អំពីសិទ្ធិរបស់សាក្សីក្នុងការបដិសេធឆ្លើយតបនឹងសំណួរណាមួយ ដោយឈរលើមូលហេតុនៃភាពដែលអាចកើតមានចំពោះការដាក់ពិរុទ្ធភាពមកលើខ្លួនឯង។ នៅថ្ងៃចុងក្រោយនៃកិច្ចដំណើរការនីតិវិធី នាសប្តាហ៍នេះ អង្គជំនុំជម្រះបានស្តាប់ទឡ្ហីករណ៍ពីក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា ស្តីពីសំណើរបស់ជនជាប់ចោទ **ខៀវ សំផន** ស្នើសុំឲ្យមានការដោះលែងខ្លួនជាបណ្តោះអាសន្ន ដោយផ្អែកលើភស្តុតាងថ្មីដែលក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** បានស្នើឲ្យមានការទទួលយក។

## ក. ការស្នើសុំឲ្យមានសេចក្តីសម្រេចសម្អាងហេតុជាលាយលក្ខណ៍អក្សរ ស្តីពីការបំបែកសំណុំរឿង០០២

នៅពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ មេធាវី **វ៉េកគែន** បានធ្វើការបដិសេធទៅនឹងការបន្តកិច្ចដំណើរការនីតិវិធី ដោយសារតែអវត្តមាននៃសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលបានរង់ចាំអស់រយៈយ៉ាងយូរពីសំណាក់អង្គជំនុំជម្រះ ស្តីពីការបំបែកសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញា **វាំងសង់ វ៉ាយជ៍ ដេស្មាឯល** ក៏បានស្នើសុំថា អង្គជំនុំជម្រះគួរតែបញ្ជាក់ថា តើភាគីត្រូវតែបន្តការយោងទៅលើកថាខណ្ឌនៃដីកាដំណោះស្រាយ ដែលបានចុះសេចក្តីសម្រេចមោឃភាព ដោយមានពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែរឬទេ? លោកប្រធានអង្គជំនុំជម្រះ មិនបានផ្តល់ការបញ្ជាក់អ្វីទេថា តើពេលណាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនឹងត្រូវចេញ ក៏ប៉ុន្តែបានអះអាងថា កថាខណ្ឌនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងវិសាលភាពសំណុំរឿង០០២/០១ អាចនឹងដូចគ្នាទៅនឹងកថាខណ្ឌដែលបានចុះក្នុងដីកាបំបែកសំណុំរឿង ដែលបានប្រកាសមោឃភាពដោយអង្គជំនុំជម្រះសាលាកំពូល។[22]

## ខ. ការអនុវត្តន៍ការតាំងសំណួរដេញដោល និងបទដ្ឋាននានា

### *ខ.១. សំណួរដែលនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១*

ក្នុងសប្តាហ៍នេះ ភាគីទាំងអស់បានបន្តលើកឡើងពីការជំទាស់ទៅនឹងការតាំងសំណួរនានា ដែលពួកគេបានតវ៉ាថា មិនពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង០០២/០១។ ជាឧទាហរណ៍ នៅថ្ងៃចន្ទ ក្នុងអំឡុងពេលនៃការសាកសួរដេញដោលសាក្សី **ឆោម សែ** ដោយខាងសហព្រះរាជអាជ្ញា មេធាវី **គូប៉េ** បានជំទាស់នឹងសំណួរជាច្រើន ដែលបានកំពុងសួរសាក្សីឲ្យធ្វើការបញ្ជាក់ថា តើស្រ្តី និងកុមារដែលស្ថិតក្នុងចំណោមជនជាតិចាំ៉យ ត្រូវបានដឹកមកមន្ទីរសន្តិសុខអូរកន្សែងដែរឬអត់? មេធាវី **គូប៉េ** បានតវ៉ាថា អត្តសញ្ញាណនៃអ្នកដែលបានចាប់ខ្លួនទាំងនេះ មិនពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធានោះទេ ហើយដូច្នេះ វាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញា **វាំងសង់ វ៉ាយជ៍ ដេស្មាឯល** បានការពារការតាំងសំណួររបស់គាត់ ដោយបានអះអាងថា គាត់គ្រាន់តែមានបំណងចង់បង្ហាញឲ្យឃើញថា តើសាក្សីបានសំដៅដល់ក្រុមចាំ៉យ ដែលដូចគ្នានឹងការលើកឡើងក្នុងឯកសារក្នុងសំណុំរឿងដែរឬអត់។ លោកប្រធានអង្គជំនុំជម្រះ បានច្រានចោលការជំទាស់របស់ក្រុមមេធាវីការពារក្តី ហើយបានអនុញ្ញាតឲ្យបន្តការតាំងសំណួរជាបន្តទៀត។

### *ខ.២. ការជំទាស់ទៅនឹងភស្តុតាងជាមតិយោបល់ និងការសន្និដ្ឋានរបស់សាក្សី*

មេធាវីការពារក្តី បានគ្រើនរម្លឹកពីឋានៈរបស់សាក្សី **ប៉ុងសួង៍** ដែលជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ ជាច្រើនលើកច្រើនសា ក្នុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់ នៅក្រោយពេលដែលសាក្សី **ប៉ុងសួង៍** បានផ្តល់យោបល់របស់គាត់ម្តងហើយម្តងទៀត ក្នុងការឆ្លើយតបទៅនឹងសំណួរដែលចោទសួរដោយចៅក្រម និងសហព្រះរាជអាជ្ញា។ នៅថ្ងៃអង្គារ មានការចោទជាសំណួរពីសំណាក់ចៅក្រម **ឡាវែន៍** ដោយបានសុំឲ្យសាក្សីផ្តល់មតិយោបល់របស់គាត់ជុំវិញ "ទស្សនៈទូទៅមកលើប្រជាជនកម្ពុជា" ដែលបណ្តាលឲ្យមេធាវីការពារក្តី **គូប៉េ** ធ្វើការគ្រើនរម្លឹកដល់អង្គជំនុំជម្រះភ្លាមថា សាក្សី **ប៉ុងសួង៍** ត្រូវបានកោះហៅមកធ្វើជាសាក្សីមិនមែនជាអ្នកជំនាញនោះទេ។ ជាការឆ្លើយតប សហព្រះរាជអាជ្ញា **វាំងសង់ វ៉ាយជ៍ ដេស្មាឯល** បានបញ្ជាក់

ថា សាក្សីអាចត្រូវបានចាត់ទុកថា អាចធ្វើ "ការវិភាគ" ដោយសារតែគាត់មានបទពិសោធន៍ក្នុងប្រទេសកម្ពុជា និងធ្លាប់បានធ្វើការស្រាវជ្រាវពីមុនមក។ មេធាវី **គូប៉េ** បានស៊ើកសម្តីថា ពាក្យ "វិភាគ" មិនមានអត្ថន័យគតិយុត្ត (អត្ថន័យច្បាប់) ក្នុង អ.វ.ត.ក នោះទេ ហើយលោក **ប៉ុងសួជ** អាចដើរតួនាទីជា "សាក្សី" ឬក៏ជា "អ្នកជំនាញ"។ បន្ទាប់ពីការពិភាក្សាសម្រេចដោយក្រុមប្រឹក្សានៃអង្គជំនុំជម្រះសាលាដំបូង ចៅក្រម **ខាតរ៉ាយថ៍** បានបញ្ជាក់ថា សាក្សីប្រាកដណាស់ដែលត្រូវបានហៅថា ជាសាក្សីធម្មតាមួយរូប មិនមែនជាអ្នកជំនាញអ្វីឡើយ។ ក៏ប៉ុន្តែ លោកស្រីបានបន្ថែមថា វាអាស្រ័យទៅលើការសម្រេចរបស់អង្គជំនុំជម្រះ ដើម្បីបញ្ជាក់ពីភាពពាក់ព័ន្ធទៅលើសំណួរនានា ហើយនិងតម្លៃសាកល្បងរបស់វា។ ការជំទាស់ដូចគ្នា ត្រូវបានលើកឡើងម្តងទៀតដោយក្រុមមេធាវីការពារក្តីទាំងពីរ ពាក់ព័ន្ធនឹងការតាំងសំណួរបន្ថែមពីសំណាក់ចៅក្រម **ឡាវែន៍** ដោយបានសុំឲ្យសាក្សីបញ្ចេញមតិយោបល់របស់ខ្លួន លើឯកសារដែលបានដាក់ជូនទៅអង្គការសហប្រជាជាតិស្តីពីប្រទេសកម្ពុជា។ លោកប្រធានអង្គជំនុំជម្រះ បានច្រានចោលការជំទាស់របស់ក្រុមមេធាវីការពារក្តី ដោយបាននិយាយថា "ហើយនេះជាការតាំងសំណួរដោយអង្គជំនុំជម្រះ ហើយចុងក្រោយនោះ គឺអង្គជំនុំជម្រះនឹងពិចារណាពិនិត្យភស្តុតាង វាយតម្លៃសក្ខីកម្មនៅពេលក្រោយ"។[23] ក៏ប៉ុន្តែ នៅថ្ងៃពុធ ក្នុងព្រឹត្តិការណ៍ដ៏កម្រមួយ អង្គជំនុំជម្រះបានគាំទ្រការជំទាស់ ដែលបានលើកឡើងដោយមេធាវី **គូប៉េ** ពាក់ព័ន្ធនឹងគោលបំណងរបស់សហព្រះរាជអាជ្ញាក្នុងការចុចសួរយកមតិយោបល់របស់សាក្សីថា តើ "អ្នកសង្កេតការណ៍សមហេតុផលម្នាក់" អាចសន្និដ្ឋានបានទេថា ការជម្លៀសជនពិការ មនុស្សងាយរងគ្រោះ អ្នកជំងឺ ... អាចធ្វើឲ្យពួកគេមានហានិភ័យខ្ពស់ដល់ស្លាប់ដែរឬទេ ?[24]

## *ខ.៣. ការជំទាស់ទៅនឹងភស្តុតាងជាពាក្យចចាមអារ៉ាម បានមកពីសាក្សី*

ក្រុមមេធាវីការពារក្តី បានលើកឡើងនូវការជំទាស់ជាច្រើន ទៅនឹងភស្តុតាងជាពាក្យចចាមអារ៉ាម នៅគ្រប់វគ្គពិភាក្សាដេញដោលក្នុងសប្តាហ៍នេះ ជាពិសេស ពាក់ព័ន្ធនឹងតម្លៃសាកល្បងនៃបទសម្ភាសន៍ជាច្រើនដែលសាក្សីបានទទួលពីជនភៀសខ្លួនកម្ពុជា។ នៅថ្ងៃពុធ មេធាវី **វែកគែន** បានជំទាស់នឹងសក្ខីកម្ម ដែលសាក្សីបានផ្តល់ ដោយបានថ្លែងថា គាត់ធ្លាប់ឃើញភស្តុតាងនៃអំពើបោសសម្អាតរបស់ខ្មែរក្រហមដោយផ្ទាល់ភ្នែក តាមការពិត គាត់គ្រាន់តែបានយោងទៅលើកំណត់ហេតុ ដែលគាត់បានស្តាប់ពីជនភៀសខ្លួន ដែលគាត់បានធ្វើបទសម្ភាសន៍តែប៉ុណ្ណោះ។ មេធាវី **គូប៉េ** ដែលបានចូលរួមជំទាស់ជាមួយនឹងមេធាវី **វែកគែន** បានបន្ថែមថា អំពីភស្តុតាង "ដែលតាមផ្លូវច្បាប់យើងហៅថា ជាពាក្យចចាមអារ៉ាម ពីរបី ឬជាន់គ្នា" បានបង្កើតជាវិមតិសង្ស័យទៅលើតម្លៃសាកល្បងនៃភស្តុតាង។[25] សហព្រះរាជអាជ្ញា បានឆ្លើយតបវិញថា កំណត់ហេតុទាំងនោះ មិនគួរជា "ពាក្យចចាមអារ៉ាមជាន់គ្នា" នោះទេ ដោយសារតែកំណត់ហេតុទាំងនោះ បានមកពីសាក្សីឃើញផ្ទាល់ភ្នែក ជាអ្នកដែលបានបញ្ជូនព័ត៌មានដោយផ្ទាល់ទៅឲ្យសាក្សី **ប៉ុងសួជ**។ ទោះបីជាអង្គជំនុំជម្រះបានចេញសេចក្តីបង្គាប់ទុកជាមុនក៏ដោយ ក៏សហព្រះរាជអាជ្ញាបានយល់ស្របក្នុងការធានាការតាំងសំណួររបស់គាត់ ដោយបញ្ជាក់ថា តើកំណត់ហេតុរបស់សាក្សីពិតជាកំណត់ហេតុដែលបានទទួលដោយផ្ទាល់ដែរឬទេ ?

## គ. សិទ្ធិរបស់សាក្សីក្នុងការមិនដាក់ពិរុទ្ធភាពមកលើខ្លួនឯង

សាក្សី **ឆោម សែ** បានប្រើប្រាស់សិទ្ធិរបស់គាត់ ដោយមិនឆ្លើយតបនឹងសំណួរនានា ដែលទំនងជាការដាក់ពិរុទ្ធភាពលើខ្លួនគាត់ នៅក្រោយពេលដែលមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា លោក **សុន អរុណ** បានចោទសួរសាក្សីថា តើគាត់ធ្លាប់ដែលបានសម្លាប់អ្នកជាប់ឃុំឃាំងក្នុងអូរកន្សែង ដែរឬទេ?

## ឃ. ការជំទាស់របស់ការិយាល័យសហព្រះរាជអាជ្ញា ទៅនឹងសារណាសន្និដ្ឋានលើវិធាន ៨៧.៤ របស់មេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា[26]

នៅពេលរសៀលថ្ងៃព្រហស្បតិ៍ មុននឹងចាប់ផ្តើមសវនាការស្តាប់ការស្នើសុំឲ្យដោះលែងជាបណ្តោះអាសន្នរបស់ជនជាប់ចោទ **ខៀវ សំផន** អង្គជំនុំជម្រះបានបដិសេធ ដោយមិនអនុញ្ញាតឲ្យទាំងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី យោងលើឯកសារនានា ដែលមានចេតនាគាំទ្រដល់ទឡ្ហីករណ៍ណាមួយ ក្នុងអំឡុងពេលនៃសវនាការនេះឡើយ។ អនុលោមតាមវិធានផ្ទៃក្នុង ៨៧.៤ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** មានបំណងចង់ដាក់ភស្តុតាង ដែលបានដកស្រង់ចេញពីសៀវភៅមួយក្បាល និពន្ធដោយអតីតសហចៅក្រមស៊ើបអង្កេតឈ្មោះ **ម៉ាកសែល ឡឺម៉ុងដ៍** (Marcel Le Monde) ។ សហព្រះរាជអាជ្ញា **ថារីក អាប់ឌុលឡាក់** (Tarik Abdulhak) បានជំទាស់នឹងពាក្យស្នើសុំនេះ ដោយឈរលើហេតុថា ពាក្យស្នើសុំនេះត្រូវបានធ្វើឡើងនៅថ្ងៃតែមួយ ដោយបានបំពានអនុស្សរណៈរបស់អង្គជំនុំជម្រះចេញកាលពីថ្ងៃមុន ដោយតម្រូវឲ្យពាក្យស្នើសុំអស់ទាំងនេះ ត្រូវធ្វើឡើងយ៉ាងហោចណាស់ពីរសប្តាហ៍ មុននឹងមានបំណងយកមកប្រើប្រាស់នោះ។[27] មេធាវី **វ៉េកតែន** បានឆ្លើយតបវិញថា គាត់បានទទួលឯកសារស្រាវជ្រាវវិទ្យាសាស្ត្រជាយូរមកហើយពីសំណាក់សហព្រះរាជអាជ្ញា ក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ ដែលការិយាល័យសហព្រះរាជអាជ្ញាមានបំណងចង់យោងក្នុងអំឡុងពេលសវនាការនេះ។ សហព្រះរាជអាជ្ញា **ថារីក** បានការពារសកម្មភាពរបស់គាត់ដោយបានតវ៉ាថា ពួកគាត់បានផ្តល់ឯកសារទាំងនោះមែនទៅឲ្យក្រុមមេធាវីការពារក្តីទុកជាការគោរពដ៏គួរសម ពីព្រោះសហព្រះរាជអាជ្ញាមិនដែលត្រូវបានអនុញ្ញាតឲ្យប្តឹងឆ្លើយតបជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹងពាក្យស្នើសុំឲ្យដោះលែងជាបណ្តោះអាសន្នរបស់ជនជាប់ចោទ **ខៀវ សំផន** ឡើយ។ ក្រោយការពិភាក្សាយ៉ាងយូររបស់ក្រុមប្រឹក្សាជំនុំជម្រះ ចៅក្រម **ខាតវ៉ាយថ៍** បានបញ្ជាក់ថា អង្គជំនុំជម្រះមិនបានដឹងពីពាក្យស្នើសុំរបស់ក្រុមមេធាវីការពារក្តីទេ រហូតទាល់តែមានលើកឡើងដោយសហព្រះរាជអាជ្ញា នៅពេលចាប់ផ្តើមនៃវគ្គសវនាការនេះ។ ហេតុដូច្នោះហើយ អង្គជំនុំជម្រះបានណែនាំដល់ភាគីទាំងអស់ថា គ្មានភាគីណាមួយអាចត្រូវបានអនុញ្ញាតយោងលើឯកសារទាំងនោះទេ រហូតទាល់តែអង្គជំនុំជម្រះមានពេលវេលាគ្រប់គ្រាន់ដើម្បីពិចារណាយ៉ាងសមរម្យលើបញ្ហាទាំងពីរនេះសិន។

## ង. សវនាការស្តាប់ពាក្យស្នើសុំឲ្យដោះលែងលោក ខៀវ សំផន ជាបណ្តោះអាសន្ន

តាមកាលវិភាគដែលបានគ្រោងទុក សវនាការតទល់គ្នាលើពាក្យស្នើសុំឲ្យដោះលែងជាបណ្តោះអាសន្នរបស់ជនជាប់ចោទ **ខៀវ សំផន** បានចាប់ផ្តើមឡើងនៅពេលរសៀលថ្ងៃព្រហស្បតិ៍នេះ ដោយបានបិទបញ្ចប់ជាមួយនឹងការធានាអះអាងពីសំណាក់អង្គជំនុំជម្រះសាលាដំបូងថា អង្គជំនុំជម្រះនឹងធ្វើការពិនិត្យលើសារណារបស់ភាគី ហើយនិងធ្វើសេចក្តីសម្រេចលើបញ្ហានេះ នៅក្នុងពេលវេលាដ៏សមស្របមួយ។[28]

មេធាវី **វែកគែន** បានលើកឡើងនូវចំណុចជាច្រើនដើម្បីគាំទ្រដល់ពាក្យស្នើសុំរបស់ខ្លួន ដោយរាប់បញ្ចូលនូវផលប៉ះពាល់នៃដីកាបំបែកសំណុំរឿង ដែលគាត់បានតវ៉ាថា វាមិនអាចធ្វើការព្យាករណ៍ទៅរួចទេថា តើពេលណាសវនាការប្រឆាំងនឹងកូនក្តីរបស់គាត់នឹងអាចត្រូវបញ្ចប់។ គាត់ក៏បានបញ្ជាក់ផងដែរ ពីរយៈពេលប្រាំឆ្នាំ និងបួនខែ ដែលកូនក្តីរបស់គាត់ត្រូវបានជាប់ឃុំឃាំង ដែលប្រការបែបនេះ គាត់បានតវ៉ាថា គឺជាការរួមផ្សំដោយសេចក្តីសម្រេចរបស់ អ.វ.ត.ក ដើម្បីផ្តល់អត្ថិភាពដល់សំណុំរឿង០០១។[29] មេធាវីបានបដិសេធដែរថា កូនក្តីរបស់គាត់ទំនងជាបានជ្រាបពីរឿងនេះ។ គាត់បានរម្លឹកអង្គជំនុំជម្រះថា កូនក្តីរបស់គាត់ បានជ្រើសរើសដោយស្ម័គ្រចិត្ត ក្នុងការបន្តរស់នៅក្នុងទីក្រុងភ្នំពេញ ក្រោយពេលនៃការបង្កើត អ.វ.ត.ក នេះឡើង ទោះបីជាគាត់បានដឹងថា គាត់អាចនឹងត្រូវបានគេចោទប្រកាន់ក៏ដោយ។ មេធាវី **វែកគែន** ក៏បានលើកឡើងផងដែរ ពីផលវិបាកនៃការពន្យារពេលឃុំឃាំង ដែលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់កូនក្តីរបស់គាត់ ដោយគាត់បានបន្ថែមទៀតថា ក្រុមគ្រួសាររបស់កូនក្តីគាត់ បានយល់ព្រមរ៉ាប់រងផ្នែកសេដ្ឋកិច្ចដើម្បីមើលថែរក្សាកូនក្តីគាត់ លើកលែងតែនៅក្នុងផ្ទះរបស់ពួកគេនៅភ្នំពេញ។ ការលើកឡើងពីក្តីកង្វល់ថា ការដោះលែងជនជាប់ចោទ **ខៀវ សំផន** អាចញុះញង់ដល់សណ្តាប់ធ្នាប់សាធារណៈ មេធាវី **វែកគែន** បានរម្លឹកពីការរកឃើញតាមរយៈការសិក្សាមួយ ដោយបានបង្ហាញថា តាមជាក់ស្តែង មានប្រជាជនកម្ពុជាតិចតួចបំផុតបានដឹងលម្អិតពីសវនាការកាត់ក្តីនេះ ហើយដូច្នេះ វាមិនទំនងជានាំឲ្យកើតមានប្រតិកម្មដ៏ហិង្សាកើតឡើងនោះឡើយ។[30] មេធាវីការពារក្តី ក៏បានបញ្ជាក់ផងដែរពីហានិភ័យសន្តិសុខ ដែលអាចកើតមានទៅលើកូនក្តីរបស់គាត់ ដោយបានរម្លឹកពីការវាយប្រហារប្រឆាំងនឹងកូនក្តីគាត់ក្នុងឆ្នាំ១៩៩១ ថាជា "ចលនាដោយហេតុផលនយោបាយ" ដែលមិនបានបង្ហាញពីសញ្ញាណនៃការវាយប្រហារណាមួយនៅថ្ងៃខាងមុខឡើយ។ គាត់ក៏បានលើកឡើងម្តងហើយម្តងទៀត ពីការបើកចិត្តដ៏ទូលាយរបស់កូនក្តីគាត់ ក្នុងការទទួលយកលក្ខខណ្ឌនានា ដែលអង្គជំនុំជម្រះបានដាក់មកលើកូនក្តីរបស់គាត់ ហេតុដូច្នោះហើយ វាជាហេតុនាំឲ្យជនជាប់ចោទ **ខៀវ សំផន** ស្នើសុំឲ្យមានការដោះលែងខ្លួនជាបណ្តោះអាសន្ននេះ។[31]

សហព្រះរាជអាជ្ញា **ចារីក** បានតវ៉ាថា លក្ខខណ្ឌដែលមាននៅក្នុងវិធាន ៦៣.៣(ខ) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញ ដោយមានហេតុផលត្រឹមត្រូវក្នុងការបន្តឃុំឃាំងជនជាប់ចោទ **ខៀវ សំផន**។[32] ក្នុងការបញ្ជាក់ពីធាតុផ្សំនីមួយៗនៃវិធាននេះ សហព្រះរាជអាជ្ញា **ចារីក** បានអះអាងថា អាចនៅតែមានហានិភ័យកើតឡើងដោយសារតែជនជាប់ចោទអាចនឹងធ្វើអ្វីម្យ៉ាងទៅលើសាក្សី។ គាត់បានលើកទឡ្ហីករណ៍ថា ប្រការបែបនេះធ្លាប់មានកើតឡើងចំពោះលោកស្រី **ស សៀក** ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់អ្នកស្រី ដែលដើរតួជាសាក្សីកាលពីឆ្នាំទៅមិញ ដោយបានបញ្ជាក់ថា ភរិយារបស់ជនជាប់ចោទ **ខៀវ សំផន** បានមកសួរសុខទុក្ខអ្នកស្រី ហើយបានសួរនាំអ្នកស្រីពីបទសម្ភាសន៍ ដែលអ្នកស្រីបានផ្តល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត។[33] ជាការឆ្លើយតបទៅនឹងចំណុចនេះ មេធាវី **វែកគែន** គូសបញ្ជាក់ថា សាក្សី **ស សៀក** ក៏បានប្រាប់អង្គជំនុំជម្រះផងដែរថា ភរិយារបស់ជនជាប់ចោទ **ខៀវ សំផន** បានលើកទឹកចិត្តអ្នកស្រីឲ្យនិយាយតែការពិត។ សហព្រះរាជអាជ្ញា **ចារីក** ក៏បានតវ៉ាផងដែរថា ការឃុំខ្លួន គឺមានភាពចាំបាច់ណាស់ដើម្បីការពារជនជាប់ចោទ ដោយយោងទៅលើការសងសឹកតាំងពីយូរមកក្នុងសង្គមកម្ពុជា ហើយនិងហានិភ័យខ្ពស់នៃការវាយប្រហារ ដែលអាចនឹងកើតមាន នៅពេលដែលជនជាប់ចោទធ្វើដំណើរពីផ្ទះទៅសវនាការទៅមកជារៀងរាល់ថ្ងៃ។[34] ដោយទទួលស្គាល់ថា ការវាយប្រហារនៅឆ្នាំ១៩៩១ ទៅលើជនជាប់ចោទ **ខៀវ សំផន** អាចបណ្តាលមកពីហេតុផលនយោបាយ សហព្រះរាជអាជ្ញា **ចារីក** បានដកស្រង់នូវចំណុចសំខាន់ៗថា ទោះបីជា

យ៉ាងនេះក្តី ប្រការបែបនេះ បានបណ្តាលឲ្យកើតមានអំពើកុប្បកម្មមួយ ដែលមានមនុស្សចំនួន ១០,០០០ នាក់ បានចូលរួម។[35] ការិយាល័យសហព្រះរាជអាជ្ញា ក៏បានគាំទ្រចំពោះមតិយោបល់របស់អង្គជំនុំជម្រះសាលាកំពូលថា ជនជាប់ចោទ **ខៀវ សំផន** ស្ថិតក្នុងស្ថានភាពហានិភ័យនៃគោលដៅវាយប្រហារ[36] ដោយគាត់ដកស្រង់សេចក្តីថ្លែងការណ៍នានា ដែលជនជាប់ចោទបានផ្តល់ឲ្យសារព័ត៌មាន ដោយបានបញ្ជាក់ពីកង្វះខាតនៃការតាមដានកិច្ចដំណើរការនីតិវិធីសវនាការរបស់ អ.វ.ត.ក។[37] មេធាវី **វែកគែន** បានឆ្លើយបដិសេធទៅនឹងចំណុចនេះក្នុងសេចក្តីថ្លែងការណ៍តប ហើយបានលើកឡើងពីបទសម្ភាសន៍មួយបន្ថែមទៀត ដែលផ្តល់ដោយវិទ្យុសំឡេងសហរដ្ឋអាមេរិក ដែលលោក **ខៀវ សំផន** បានបញ្ជាក់ពីឆន្ទៈគោរពតាមការកោះហៅរបស់ អ.វ.ត.ក។[38]

ដោយបានបញ្ជាក់ពីទទ្បីករណ៍របស់ក្រុមមេធាវីការពារក្តី ស្តីពីភាពមិនអាចព្យាករណ៍បាន និងការពន្យារពេលសវនាការ សហព្រះរាជអាជ្ញា **ចារីក** បានតវ៉ាពីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (Eropean Court of Human Rights) ដែលបានដកស្រង់ដោយក្រុមមេធាវីការពារក្តី ពាក់ព័ន្ធទៅនឹងសំណុំរឿងក្នុងស្រុក ស្តីពីការឃុំខ្លួនមុនការជំនុំជម្រះ ក្នុងដំណាក់កាលស៊ើបអង្កេត ហើយដូច្នេះ វាគ្មានភាពពាក់ព័ន្ធគ្នាទាល់តែសោះ។[39] បន្ទាប់មក មេធាវី **វែកគែន** បានឆ្លើយបដិសេធតបនឹងចំណុចនេះ ដោយបានតវ៉ាថា សេចក្តីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ទាក់ទិននឹង "សាលក្រមកាត់សេចក្តី" ក្នុងដំណាក់កាលជំនុំជម្រះ គឺមានភាពពាក់ព័ន្ធគ្នា។[40] ដោយបានបន្ថែមថា អង្គជំនុំជម្រះបានបន្តកិច្ចដំណើរការនីតិវិធីឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ដោយបានធ្វើការពិចារណាលើភាពស្មុគស្មាញនៃសំណុំរឿងនោះ សហព្រះរាជអាជ្ញា **ចារីក** ក៏បានដកស្រង់ដីកាបំបែកសំណុំរឿងថ្មីរបស់អង្គជំនុំជម្រះ ធ្វើជាភស្តុតាងបញ្ជាក់ថា ការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការ អាចនឹងធ្វើការព្យាករណ៍បាន។[41] ជាងនេះទៅទៀត ជាការប្រៀបធៀបទៅនឹងតុលាការអន្តរជាតិដទៃទៀត សហព្រះរាជអាជ្ញា **ចារីក** បានតវ៉ាថា អំឡុងពេលនៃការឃុំខ្លួន គឺមិនមែនជារឿងខុសធម្មតាអ្វីនោះទេ។[42] ទាក់ទងនឹងការចោទប្រកាន់របស់មេធាវី **វែកគែន** ដែលថា ការឃុំខ្លួនជនជាប់ចោទត្រូវបានអូសបន្លាយពេល ដោយសារតែសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការដំណើរការសវនាការសំណុំរឿង០០១ មុន សហព្រះរាជអាជ្ញា **ចារីក** បានបញ្ជាក់ថា លំដាប់លំដោយនៃទទ្បីករណ៍ទាំងនេះ គឺបានមកពីសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេត លោក **ម៉ាកសែល ឡឺម៉ុងដ៍** ដែលគាត់មិនទាន់មានឱកាស សម្រាប់ធ្វើការសាកសួរដេញដោលនោះឡើយ (សូមមើលផ្នែកទី៣.ឃ)។ ប៉ុន្តែ គាត់បានចង្អុលបង្ហាញថា មានឯកសារនៃសំណុំរឿង០០១យ៉ាងច្រើន មានការជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេតលើសំណុំរឿង០០២នេះ។

## ផ្នែកទី ៤៖ ការគ្រប់គ្រងសវនាការ

សប្តាហ៍នេះ អង្គជំនុំជម្រះបានបិទបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីពីររូប ដូចដែលបានគ្រោងទុកតាមកាលវិភាគ ហើយនិងបានស្តាប់ពីសេចក្តីសម្អាងហេតុពាក់ព័ន្ធនឹងពាក្យបណ្តឹងរបស់ជនជាប់ចោទលោក **ខៀវ សំផន** ស្នើសុំឲ្យមានការដោះលែងជាបណ្តោះអាសន្ន។ ជាការគួរឲ្យកត់សម្គាល់ ទាក់ទិននឹងការយកចិត្តទុកដាក់ពីបញ្ហាពេលវេលា អង្គជំនុំជម្រះបានបន្តកិច្ចដំណើរការនីតិវិធីបានយ៉ាងមានប្រសិទ្ធភាព ទោះបីជាមានបញ្ហាបកប្រែភាសា និងបញ្ហាបច្ចេកទេស បានបង្កការលំបាកខ្លះៗក៏ដោយ ជាពិសេស ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី **ប៉ុងសូដ៍** (សូមមើលផ្នែកទី៤.ឃ)។

## ក. វត្តមាន

ជនជាប់ចោទ នួន ជា បានចូលរួមតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងនៅក្រោមសាលសវនាការពេញមួយសប្តាហ៍ ដោយសារតែបញ្ហាសុខភាពរបស់គាត់នៅតែបន្តកើតមាន។ រីឯជនជាប់ចោទ **ខៀវ សំផន** វិញ មានវត្តមាននៅក្នុងសាលសវនាការគ្រប់វគ្គពិភាក្សាដេញដោលក្តីទាំងអស់។

**វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖** យ៉ាងហោចណាស់ មានដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជា ៣០នាក់ (រាប់បញ្ចូលទាំងជនជាតិចាមផងដែរ) ដែលមកពីខេត្តផ្សេងៗគ្នា បានចូលរួមតាមដានកិច្ចដំណើរការនីតិវិធីសវនាការជារៀងរាល់ថ្ងៃ ក្នុងសាលសវនាការ ឬសាលសាធារណជន។

**វត្តមានរបស់ភាគី៖** គ្រប់ភាគីទាំងអស់ បានតំណាងឲ្យកូនក្តីរបស់ខ្លួនជាប្រក្រតី ពេញមួយសប្តាហ៍នេះ។

**វត្តមានរបស់សាធារណជន៖**

| កាលបរិច្ឆេទ | សវនាការពេលព្រឹក | សវនាការពេលរសៀល |
|---|---|---|
| ថ្ងៃចន្ទ<br>០៨/០៤/២០១៣ | ▪ អ្នកភូមិចំនួន ៣០០នាក់ មកពីស្រុកបុរីជលសារ ខេត្តតាកែវ<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ១៥នាក់ | ▪ អ្នកភូមិចំនួន ២០០នាក់ មកពីស្រុកបុរីជលសារ ខេត្តតាកែវ<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ៨នាក់ |
| ថ្ងៃអង្គារ<br>០៩/០៤/២០១៣ | ▪ អ្នកភូមិចំនួន ៣២០នាក់ មកពីស្រុកបុរីជលសារ ខេត្តតាកែវ<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ១៧នាក់ | ▪ អ្នកភូមិចំនួន ១០០នាក់ មកពីស្រុកបុរីជលសារ ខេត្តតាកែវ<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ៦នាក់ |
| ថ្ងៃពុធ<br>១០/០៤/២០១៣ | ▪ សិស្សានុសិស្សចំនួន ៣៥០នាក់ មកពីវិទ្យាល័យទូកមាស ខេត្តកំពត<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ១៣នាក់ | ▪ សិស្សានុសិស្សចំនួន ៣០០ នាក់ មកពីវិទ្យាល័យទូកមាស ខេត្តកំពត<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ១០នាក់ |
| ថ្ងៃព្រហស្បតិ៍<br>១១/០៤/២០១៣ | ▪ និស្សិតចំនួន ២០០នាក់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម<br>▪ មានយុវជនចំនួន ១៥០នាក់ មកពីសហព័ន្ធយុវជនរដ្ឋាភិបាលតាមបណ្តាខេត្តផ្សេងៗគ្នា<br>▪ មានយុវជនកាយរិទ្ធចំនួន ៣០នាក់ មកពីភ្នំពេញ<br>▪ អ្នកសង្កេតការណ៍បរទេសចំនួន ៦នាក់ | ▪ អ្នកសង្កេតការណ៍បរទេសចំនួន ៤នាក់ |

## ខ. ការគ្រប់គ្រងពេលវេលា

នាសប្តាហ៍នេះ អង្គជំនុំជម្រះបានបើកកិច្ចដំណើរការនីតិវិធីចាប់ពីថ្ងៃចន្ទ រហូតដល់ថ្ងៃព្រហស្បតិ៍។ ថ្វីបើមានការពិភាក្សាតិចតួចមួយចំនួន ទាក់ទងនឹងចំនួនពេលវេលា ដែលបានផ្តល់ជូនឲ្យខាងការិយាល័យសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីក៏ដោយ ក៏កិច្ចដំណើរការនីតិវិធីបានបញ្ចប់ទៅតាមកាលវិភាគដែលបានគ្រោងទុកដែរ។

## គ. បញ្ហាបកប្រែភាសា និងបច្ចេកទេស

មានបញ្ហាបច្ចេកទេសតិចតួចមួយចំនួនទាក់ទងនឹងប្រព័ន្ធសោតទស្សន៍ បានកើតឡើងក្នុងសប្តាហ៍នេះ ក៏ប៉ុន្តែត្រូវបានធ្វើការកែលម្អភ្លាមៗ។[43] បញ្ហាបកប្រែភាសា ក៏បានកើតឡើងផងដែរ ពេញមួយសប្តាហ៍នេះ ប៉ុន្តែវាបានស្តែងឲ្យឃើញយ៉ាងច្បាស់ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី **ប៉ុងសួង៍**។[44] ការផ្លាស់ប្តូររបស់សាក្សី **ប៉ុងសួង៍** ក្នុងការនិយាយភាសាបារាំងផង និងខ្មែរផង បូករួមទាំង ចេតនាខ្ជីខ្ជាក្នុងការបើកឧបករណ៍បំពងសំឡេងរបស់គាត់ មុនពេលនៃការនិយាយយ៉ាងលឿនផងនោះ បានបណ្តាលឲ្យមានការពិបាកយ៉ាងខ្លាំងចំពោះអ្នកបកប្រែភាសា។ នៅពេលចាប់ផ្តើមសក្ខីកម្មរបស់សាក្សី **ប៉ុងសួង៍** លោកប្រធានអង្គជំនុំជម្រះ បានព្រមានដល់សាក្សីថា ទោះបីជាគាត់មានសេរីភាពជ្រើសរើសភាសាណាមួយ ដែលគាត់ចង់ប្រើប្រាស់សម្រាប់ការផ្តល់សក្ខីកម្មក៏ដោយ គឺវាគ្មានការរើសអើងនោះទេ ប៉ុន្តែដើម្បីជៀសវាងនូវការភាន់ច្រឡំចំពោះអ្នកបកប្រែភាសា ដូចនេះ គាត់នឹងមិនត្រូវបានអនុញ្ញាតឲ្យធ្វើការផ្លាស់ប្តូរទៅនិយាយភាសាពីរក្នុងពេលតែមួយនោះឡើយ។ ពេញមួយថ្ងៃដំបូងនៃសក្ខីកម្មរបស់គាត់ សាក្សីបាននិយាយភាសាខ្មែរជាប់ជានិច្ច។ ប៉ុន្តែមានពេលខ្លះ នៅពេលដែលបានឮការបកប្រែពាក្យសម្តីរបស់គាត់ពីភាសាខ្មែរទៅភាសាបារាំង សាក្សីបានសម្តែងឲ្យឃើញពីការខកចិត្តរបស់គាត់ ហើយបានប្រកាសថា អ្នកបកប្រែភាសា បានបកប្រែពាក្យសម្តីរបស់គាត់ខុស។ ចាប់ពីថ្ងៃពុធ គាត់បានធ្វើការផ្លាស់ប្តូរដោយនិយាយភាសាពីរ ហើយជាលទ្ធផល មានការប្រើប្រាស់ពេលវេលាយ៉ាងច្រើន ដើម្បីសួរបញ្ជាក់ពីកាលបរិច្ឆេទ អង្គហេតុ និងការឆ្លើយតបរបស់សាក្សី **ប៉ុងសួង៍** ដែលហាក់ដូចជាមិនបានឆ្លើយតបនឹងសំណួរ ដែលបានចោទសួរនោះ។ នៅពេលរសៀលថ្ងៃពុធ ក្រោយពីបានលើកឡើងម្តងហើយម្តងទៀត ពីគោលបំណងដើម្បីសុំឲ្យមានការបញ្ជាក់លើចម្លើយមួយ មេធាវី **វែកគែន** បានចោទសួរទៅសាក្សីថា តើគាត់អាចសូមជួយឆ្លើយជាភាសាបារាំងបានដែរឬទេ ដោយនិយាយថា "លោកឪពុកដឹងទេថា លោកឪពុកនិយាយអ្វី ក៏ប៉ុន្តែអ្វីដែលខ្ញុំឮនេះ វាខុសពីអ្វីដែលលោកឪពុកនិយាយ"។[45] នៅចុងបញ្ចប់ នៅថ្ងៃចុងក្រោយនៃការផ្តល់សក្ខីកម្មរបស់គាត់ ទោះបីជាមានបញ្ជាក់ពីការសន្និដ្ឋានថា គាត់បានបង្ហាញពីការគាំទ្រដល់ក្រុមមេធាវីការពារក្តី ប្រសិនបើគាត់ផ្តល់សក្ខីកម្មជាភាសាបារាំងក៏ដោយ ក៏សាក្សី **ប៉ុងសួង៍** បានបញ្ចប់ការផ្តល់សក្ខីកម្មជាភាសាកំណើតរបស់គាត់ផងដែរ (ភាសាបារាំង)។ ប្រការបែបនេះ បានបង្ហាញឲ្យឃើញពីការពន្លឿនចំពោះការសាកសួរដេញដោល ហើយបានកាត់បន្ថយការភាន់ច្រឡំឲ្យមកត្រឹមកម្រិតតិចតួចបំផុត នៅក្នុងសក្ខីកម្មរបស់គាត់ តែទោះបីជាយ៉ាងនេះក៏ដោយ សវនាការនេះនៅសល់ពេលតែពីរវគ្គប៉ុណ្ណោះ សម្រាប់ការសួរដេញដោលសាក្សី។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្ដើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃចន្ទ ០៨/០៤/១៣ | ៩:០៧ | ១០:៤១-១១:១៣ | ១២:០៣-១៣:៣០ | ១៤:៣៩-១៥:០១ | ១៥:៤៧ | ៤ម៉ោង និង ១៩នាទី |
| ថ្ងៃអង្គារ ០៩/០៤/១៣ | ៩:០៨ | ១០:៣៣-១០:៥៦ | ១២:០៤-១៣:៤៣ | ១៤:៤១-១៥:០៣ | ១៦:១១ | ៤ម៉ោង និង ៣៩នាទី |
| ថ្ងៃពុធ ១០/០៤/១៣ | ៩:០៣ | ១០:៣១-១០:៥៤ | ១២:០៨-១៣:៤៣ | ១៤:៤៣-១៥:០៥ | ១៦:០១ | ៤ម៉ោង និង ៤៨នាទី |
| ថ្ងៃព្រហស្បតិ៍ ១១/០៤/១៣ | ៩:០៣ | ១០:២៩-១០:៥៥ | ១១:៥៨-១៣:៣៥ | ១៤:៤៨-១៥:០៤ | ១៦:០៥ | ៤ម៉ោងនិង ៤៣នាទី |

*រយៈពេលសវនាការជាមធ្យម* — *៤ម៉ោង និង៣៧នាទី*
*រយៈពេលសវនាការសរុបក្នុងសប្ដាហ៍នេះ* — *១៨ម៉ោង និង២៩នាទី*
*ចំនួនម៉ោង ថ្ងៃ និងសប្ដាហ៍នៃសវនាការ* — *៧០៧ម៉ោង និង២៧នាទី*

***រយៈពេលសវនាការចំនួន ១៦៤ថ្ងៃ អំឡុងពេល ៥២សប្ដាហ៍***

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Chhaya Chhin, Phalla Chhoeun, Pheakdey Chum, Faith Suzzette Delos Reyes, Melanie Hyde, Aviva Nababan, Noyel Ry, Sarun Sous, Kimsan Soy, Chhayrath Tan, and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT

TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

1 Trial Chamber. Transcript of Trial Proceedings (8 April 2013). E1/177.1 [hereinafter 8 APRIL **TRANSCRIPT**]. Lines 16-17. 28.

2 See CASE 002 KRT TRIAL MONITOR, Issue 48, Hearing on Evidence Week 43 (8-11 January 2013), [hereinafter ISSUE 48], II.C.

3 Chhaom Se was examined in the following order: International Prosecutor Vincent de Wilde d'Estmael; National Civil Parties Lawyer Chhet Vanly; International Co-Lawyer for Nuon Chea, Victor Koppe; National Co-Lawyer for Nuon Chea, Son Arun; International Co-Lawyer for Khieu Samphan, Arthur Vercken.

4 8 APRIL TRANSCRIPT. Lines 15-19. 38.

5 Ibid, lines 7-16. 43.

6 When Prosecutor de Wilde d'Estmael explained who Vy was, the French-to-English translation was inconsistent as to whether he was a solider in the Northwest Zone or the Northeast Zone.

7 8 APRIL TRANSCRIPT. Lines. 8-10. 23.

8 ISSUE 48, II.C.1

9 8 APRIL TRANSCRIPT. Line 4. 73.

10 François Ponchaud was examined in the following order: President Nil Nonn; Judge Jean-Marc Lavergne; International Prosecutor Vincent de Wilde d'Estmael; National Prosecutor Dararasmey Chan; National Civil Party Lawyer Moch Sovannary; International Civil Party Lead Co-Lawyer Elisabeth Simonneau-Fort; National Co-Lawyer for Khieu Samphan, Kong Sam Onn; International Co-Lawyer for Khieu Samphan, Arthur Vercken; and International Co-Lawyer for Nuon Chea, Victor Koppe

11 Trial Chamber. Transcript of Trial Proceedings (9 April 2013). E1/178.1 [hereinafter 9 APRIL TRANSCRIPT]. Lines 120-22. 22.

12 Trial Chamber. Transcript of Trial Proceedings (10 April 2013). E1/179.1 [hereinafter 10 APRIL TRANSCRIPT]. Lines 8-10. 23.

13 10 APRIL TRANSCRIPT. Lines 1-3. 43.

14 Ibid, lines 17-18. 56.

15 Ibid, lines 1-7. 37.

16 Ibid, lines 7-8. 72.

17 Ibid, lines 24-25. 95.

18 Trial Chamber. Transcript of Trial Proceedings (11 April 2013). E1/180.1 [hereinafter 11 APRILTRANSCRIPT]. Line 17. 50.

19 11 APRIL TRANSCRIPT. Lines 20-21. 19.

20 Ibid, lines 8-10. 37.

21 Ibid, lines 6-9. 22.

22 See Trial Chamber. "List of Paragraphs and Portions of the Closing Order Relevant to Case 002/01 amended further to the Trial Chamber's Decision on IENG Thirith's Fitness to Stand Trial (E138) and the Trial Chamber's Decision on Co-Prosecutor's Request to Include Additional Crime Sites within the Scope of Trial In Case 002/01 (E163)" (8 October 2012). E124/7.3.

23 9 APRIL TRANSCRIPT. Lines 14-16. 99.

24 10 APRIL TRANSCRIPT. Lines 18-23. 17.

25 Ibid, lines 1-7. 32.

26 See Internal Rules of the Extraordinary Chambers In The Courts of Cambodia, Revision 8, as revised on 3 August 2011 [hereinafter INTERNAL RULES] Rule 87.4. The rule allows the introduction of new witnesses and evidence by the parties at the trial stage, subject to the Chamber's approval after measured against the standards in Rule 87.3 The Parties should also prove that the new evidence or testimony was not available prior to the trial stage. Rule 87.3. reserves the right for the Trial Chamber to deny any request for evidence or testimony if it is irrelevant or repetitious; impossible to obtain within a reasonable time; unsuitable to prove the facts it purports to prove; not allowed under the law; or intended to prolong proceedings or is frivolous.

27 The Prosecutor cited Trial Chamber Memorandum with document number E276/2. Paragraph 2 of the document states, "[F]inally, parties must lodge a consolidated Internal Rule 87(4) request for all new documents intended for use during the testimony of a witness at least two weeks before his or her scheduled appearance (E218, para. 22)." See Trial Chamber. "Response to the Internal Rule 87(4) Requests of the Co Prosecutors, Nuon Chea, and Khieu Samphan (E236/4/41, E265, E271, E276, E276/1). (10 April 2013). E276/2.

[28] The hearing was scheduled for adversarial debate on the application filed by the Khieu Samphan's Defense on 29 March 2013. See Lawyers for Mr. Khieu Samphan. "Application for Khieu Samphan's Immediate Release on Bail" (29 March 2013). E 275. [hereianfter APPLICATION FOR RELEASE].

[29] Vercken claimed that Khieu Samphan had been arrested at the same time with Kaing Gek Eav alias Duch, the Accused of Case 001, yet he was detained while the OCIJ was completing the Case 001 investigation.

[30] In the written submission, Khieu Samphan's Defense team cited research from Human Rights Center of University of California at Berkeley dated June 2011, allegedly showing that in 2010 only 11 per cent of the Cambodian population could name the Accused and only 16 per cent considered DK crimes as important. See APPLICATION FOR RELEASE para 35.

[31] Upon questioning by Judge Cartwright, counsel Vercken clarified that the Accused could come to the Court either by his own means or by transportation provided by the Court. The counsel also stressed the indigence of the Accused to the Chamber referring to documentary evidence provided to the court. Khieu Samphan also took the floor, stating that he would be provided for by his children, he did not have a passport, and could go to the court by motorcycle with his wife.

[32] INTERNAL RULES Rule 63.3.B on Provisional Detention provides that provisional detention may be imposed to i) prevent the Charged Person from exerting pressure on any witnesses or Victims, or prevent any collusion between the Charged Person and accomplices of crimes falling within the jurisdiction of the ECCC; ii) preserve evidence or prevent the destruction of any evidence; iii) ensure the presence of the Charged Person during the proceedings; iv) protect the security of the Charged Person; or v) preserve public order.

[33] See CASE 002 KRT TRIAL MONITOR, Issue 32, Hearing on Evidence Week 43 (8-11 January 2013). Page 11

[34] The Prosecutor cited Document No. E50/3/1/1.1.4, a December 2010 study stating that approximately 40 per cent of the population still "harbor feelings of revenge towards the former Khmer Rouge and the Khmer Rouge leadership."

[35] The International Prosecutor cited Document No. D29, Attachment 96, that provided an account of the incident. Further he described that in year 2000 Khieu Samphan made a statement recorded Document D29, Attachment 95, that he would only provide information on the Khmer Rouge if granted protection.

[36] Abdulhak cited paragraph 54 of the Supreme Court Decision, which states "[T]he reasons have less to do with the general risk of the Accused absconding in the face of the severity of potential penalty, and more to do with therisk of the Accused becoming unavailable for trial. Facts transpiring from the case file demonstrate that the trial in Case 002 is an enormous organizational and logistical undertaking involving four accused, most of whom have health problems, and numerous civil parties and multi-person legal teams. Even a single instance of an accused failing to appear before the court might undermine the prospect of arriving at the judgment within a reasonable time. The goal of speedy proceedings may be easily frustrated if the Accused goes into hiding, decides to disregard summons or even temporarily is prevented from attending a hearing." See The Supreme Court Chamber. "Decision on Immediate Appeal by Khieu Samphan on Application for Release" (06 June 2013). E50/3/1/4.

[37] The International Prosecutor cited Khieu Samphan's interviews in October 2007 (Document E3/583), November 2006 (Document E3/108) and an unspecified interview (D313.11.1).

[38] Counsel Vercken did not provide the date of the interview but identified the Document number as E3/588. Counsel Vercken also cited an article from "The Cambodia Daily", (no document number provided) which he claimed stated that "Khieu Samphan was said to cooperate with the tribunal."

[39] The International Prosecutor also cited some of the European Court of Human Rights cases relied on by the Khieu Samphan Defense Team in relation to the observation of human liberty, standards to ensure foreseeabilty and legal certainty, namely Case of Velichko v. Russia Judgment, ECHR, 15 January 2013 ("Velichko Case"), para. 67; Case of Tsitsiriggos v.Greece, Judgment, ECHR, 17 January 2012, paras. 47-48; Case of Tsarkov v. Russia, Judgment, ECHR, 16 July 2009 ("Tsarkov Case"). See APPLICATION FOR RELEASE para 1719 and the accompanying footnotes.

[40] Arthur Vercken specifically referred to the European Court of Human Right's decision, Soria Valderrama case of 26 January 2012.

[41] See CASE 002 KRT TRIAL MONITOR, Issue 55, Hearing on Evidence Week 50 (25-29 March 2013).

[42] International Prosecutor Abdulhak expounded before the Chamber that the OCP's review showed that at the ICTY in more than 50 cases, the accused persons had been detained five years or longer and at the ICTR in at least 31 cases.

[43] For example, during the first session on Monday an audio system malfunction prevented sound from reaching the French interpreters. This occurred again on Thursday when Prosecutor Abdulhak reported hearing French in his receiver.

[44] For example, responding to questions from CPLCL Simonneau-Fort, Ponchaud's response in Khmer of "2000 families" was incorrectly translated into English as "1000 families."

[45] 10 APRIL TRANSCRIPT. Lines 7-9. 86.